មជ្ឈមណ្ឌលឯកសារកម្ពុជា

# បូជនីយដ្ឋាន

## ខេត្តបន្ទាយមានជ័យ

### ១) វត្តកណ្តាល

ឆ្អឹងដែលជញ្ជូនមកពីទីតាំងសម្លាប់នៅព្រៃគោកត្រាច គោកតាម៉ុល និងពីកន្លែងផ្សេងទៀតក្នុងស្រុកភ្នំស្រុក ត្រូវយកមកដាក់តម្កល់នៅក្នុងបូជនីយដ្ឋានក្នុងវត្តកណ្តាល ។ វត្តនេះមានទីតាំងនៅភូមិស្រះឈូក ឃុំ ស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ មានឆ្អឹងលលាដ៏ក្បាល និងឆ្អឹងអវៈយវៈជាច្រើនដែលដាក់តម្កល់ក្នុងបូជនីយដ្ឋាននេះ ត្រូវទទួលរងការបែកបាក់ និងពុកផុយ ។

*អ្នកផ្តល់ពត៌មានៈ*

១) ឈុំ រួម ភេទប្រុស ជាចៅហ្វាយស្រុកភ្នំស្រុក ។

២) គាត់ ឈឿម ភេទប្រុស រស់នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ។

៣) គាន់ មិញ ភេទប្រុស រស់នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ។

*ទិន្នន័យកុំព្យូទ័រៈ*

រយៈកម្ពស់(N) 13º 44' 38:15", រយៈទទឹង(E) 103º 20' 75:37" និងលេខកូដ (ID No.) 010304 ។

### ២) វត្តសុភមង្គល

ចិន សារ៉ាង បច្ចុប្បន្នមានអាយុ៦៥ឆ្នាំ មានទីលំនៅភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានចូលរួមគាស់រណ្តៅសាកសពជាមួយប្រជាជនដទៃទៀតកាលពីឆ្នាំ១៩៨៣ នៅទីតាំងសម្លាប់ដែលស្ថិតនៅចន្លោះភ្នំកូនខ្លា ភ្នំស្វាយ ភ្នំអញ្ចាំង និងរណ្តៅនៅតាមជើងភ្នំក្នុងចម្ការខ្នុរ ដែលបច្ចុប្បន្នជាចម្ការដំណាំរបស់អ្នកស្រុក ដើម្បីរកមាសដែលជាប់នៅនឹងខ្លួនសាកសព ។ ឆ្អឹងដែលសេសសល់ក្រោយការគាស់ ត្រូវប្រជាជនប្រមូលនិងជញ្ជូនយកមកដាក់តម្កល់ទុកនៅក្នុងបូជនីយដានក្នុងវត្តសុភមង្គលដែលស្ថិតនៅក្នុងភូមិ និងឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ កន្លែងតម្កល់អដ្ឋិធាតុថ្មីសន្ទាងមួយមានពីរជាន់ធ្វើពីបេតុង បានត្រូវធ្វើឡើងដើម្បីដាក់តម្កល់ឆ្អឹងដែលនៅសេសសល់ពីការលួច និងបំផ្លាញដោយភាពកង្វះថែទាំ ។

*អ្នកផ្តល់ពត៌មានៈ*

១) ចិន សារ៉ាង អាយុ៦៥ឆ្នាំ ភេទប្រុស នៅភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ។

២) សាន មាន អាយុ៦៨ឆ្នាំ អាចារ្យវត្តសុភមង្គល រស់នៅភូមិខ្នាំង ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 13º 35' 12:72", រយៈទទឹង(E) 102º 57' 43:08" និងលេខកូដ (ID No.) 010304 ។

# ខេត្តបាត់ដំបង

## ៣) ល្អាងគីរីរម្យ

អដ្ឋិធាតុជនរងគ្រោះដែលស្ថិតនៅតាមល្អាងផ្សេងៗនាភ្នំសំពៅ ត្រូវបានប្រមូលមកដាក់តម្កល់នៅកន្លែងតែមួយគឺ ល្អាងគីរីរម្យ ។ ល្អាងនេះមានតម្កល់អដ្ឋិធាតុមិនច្រើនប៉ុន្មានទេ ហើយក៏ពុំមានសាងសង់ជាមន្ទីរបូជនីយដ្ឋានសម្រាប់ដាក់តម្កល់ដែរ ។ ជារៀងរាល់ឆ្នាំ ជាពិសេសនៅរដូវភ្ជុំបិណ្ឌ និងចូលឆ្នាំ ប្រជាជនដែលរស់នៅក្បែរទីនោះ បាននិមន្តព្រះសង្ឃមកសូត្រមន្តបង្សុកូលជូនដល់វិញ្ញាណក្ខន្ធអ្នកស្លាប់ក្នុងល្អាងនេះកាលពីរបបខ្មែរក្រហម ព្រមទាំងមានម្ហូបនំចំណីផង ។

**អ្នកផ្តល់ពត៌មានៈ**

ប្រាក់ រ៉ុម អាយុ៦៧ឆ្នាំ ភេទប្រុស នៅភូមិសំពៅ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 13º 01' 16:50", រយៈទទឹង(E) 103º 05' 51:97" និងលេខកូដ (ID No.) 020103 ។

## ៤) វត្តសំរោង

នៅឆ្នាំ១៩៨០ អដ្ឋិធាតុជាច្រើនត្រូវបានគាស់ឡើង ។ ឆ្អឹងលលាដ៍ក្បាល និងឆ្អឹងដងខ្លួនត្រូវបានបោះគរនៅលើមាត់រណ្តៅដែលគាស់ ។ រណ្តៅជាច្រើនដែលស្ថិតនៅជុំវិញមន្ទីរបូជនីយដ្ឋាន ត្រូវគាស់ទាំងអស់ ហើយស្លាកស្នាមនៅមិនទាន់រលប់នៅឡើយ ។ នៅឆ្នាំ១៩៨០ បូជនីយដ្ឋាននេះបានត្រូវសាងសង់ដើម្បីដាក់អដ្ឋិធាតុ ហើយមកដល់ពេលនេះ បូជនីយដ្ឋាននេះបានក្លាយទៅជាសំណង់ចាស់ គ្មានជញ្ជាំង និងមានសេសសល់តែគំនរឆ្អឹងតិចតួចប៉ុណ្ណោះ ។

**អ្នកផ្តល់ពត៌មានៈ**

១)ឆន សុវត្ថិ សព្វថ្ងៃរស់នៅភូមិសំរោង ឃុំសំរោង ស្រុកឯកភ្នំ ខេត្តបាត់ដំបង សព្វថ្ងៃអាចារ្យវត្តសំរោង ។

២)យុត ឆួន ភេទប្រុស អាយុ៧៣ឆ្នាំ រស់នៅភូមិតាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

៣) ញឹម រ៉ាន់ ភេទប្រុស អាយុ៦៩ឆ្នាំ រស់នៅភូមិកហាល់ ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 13º 07' 44:27", រយៈទទឹង(E) 103º 13' 05:47" និងលេខកូដ (ID No.) 020502 ។

## ៥) វត្តគាលាស់ចាស់

រណ្តៅនៅជុំវិញបរិវេណវត្តគាលាស់ចាស់ជាច្រើន សុទ្ធតែត្រូវប្រជាជនគាស់នៅក្រោយឆ្នាំ ១៩៧៩ ។ ឆ្អឹងជាច្រើនដែលប្រជាជនបោះគរនៅមាត់រណ្តៅ ត្រូវអាជ្ញាធរមូលដ្ឋានប្រមែប្រមូលយកទៅដាក់នៅក្នុងបូជនីយដ្ឋានមួយដែលបានសាងសង់ឡើងនៅក្រោយការគាស់បន្តិច ។ ចំនួនអដ្ឋិធាតុដែលគាស់បាននេះ មានចំនួនច្រើន ។

**អ្នកផ្តល់ពត៌មានៈ**

ហ៊ុយ គ្រឹម ភេទប្រុស អាយុ៥១ឆ្នាំ ជាអនុប្រធានការិយាល័យស្រុកមោងឫស្សី ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 48' 44:98", រយៈទទឹង(E) 103º 28' 13:04" និងលេខកូដ (ID No.) 020602 ។

## ៦) វត្តជ្រៃ

មន្ទីរបូជនីយដ្ឋានវត្តជ្រៃ មានទីតាំងស្ថិតនៅភូមិជ្រៃ ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ អដ្ឋិធាតុដែលប្រជាជនបានគាស់ចេញពីរណ្តៅនៅជុំវិញបរិវេណវត្ត ត្រូវនាំយកមកតម្កល់ទុកនៅក្នុងមន្ទីរបូជនីយដ្ឋានដែលពីមុនជាអតីតខ្ទមសម្រាប់អ្នកបួសស្នាក់នៅដើម្បីរៀនធម៌ ។ ដោយសារតែខ្ទមនេះមានសភាពទ្រុឌទ្រោមណាស់ទៅហើយ អដ្ឋិធាតុភាគច្រើនត្រូវបាត់បង់អស់ ។

**អ្នកផ្តល់ពត៌មានៈ**

ហ៊ុយ គ្រឹម ភេទប្រុស អាយុ៥១ឆ្នាំ ជាអនុប្រធានការិយាល័យស្រុកមោងឫស្សី ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 46' 50:51", រយៈទទឹង(E) 103º 28' 20:45" និងលេខកូដ (ID No.) 020604 ។

## ៧) វត្តសម្តេចមុនី

អដ្ឋិធាតុរាយប៉ាយមួយចំនួនដែលស្ថិតនៅក្នុងបូជនីយដ្ឋានវត្តសម្តេចមុនី ជាអដ្ឋិធាតុដែលប្រជាជនគាស់បានពីរណ្តៅជុំវិញបរិវេណវត្តសម្តេចមុនីកាលពីអំឡុងឆ្នាំ១៩៨០ ។ ឆ្អឹងភាគច្រើនត្រូវបែកបាក់ជាកំណាត់ៗ និងមានសភាពពុកផុយ ។ អដ្ឋិធាតុយ៉ាងច្រើនកាលពីមុន ឥឡូវនេះនៅសល់តែបន្តិចប៉ុណ្ណោះ ។

*ទិត ហឿម ជាអតីតអ្នកផ្សំថ្នាំបូរាណប្រចាំនៅវត្តសម្តេចមុនី និងបច្ចុប្បន្នជាគ្រូសូត្រនៅវត្តនេះបានប្រាប់ថា អដ្ឋិធាតុដែលត្រូវបានបំផ្លាញទាំងនោះ គឺដោយសារកង្វះការថែទាំ ។ វត្តសម្តេចមុនី មានទីតាំងស្ថិតនៅក្នុងភូមិសម្តេច ឃុំតាប៉ុន ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។*

***អ្នកផ្តល់ព័ត៌មានៈ***

*១) ទិត ហឿម អាយុ៦៧ឆ្នាំ ភេទប្រុស ជាគ្រូសូត្រនៅវត្តសម្តេច(មុនី) ។*

*២) ម៉ៅ សុង អាយុ៦៩ឆ្នាំ ភេទប្រុស ជាគណកម្មការវត្តសម្តេច(មុនី) ។*

*៣) កែន ហៀប អាយុ៥៦ឆ្នាំ ភេទប្រុស ជាមន្ត្រីចូលនិវត្តន៍ ។*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់*(N) 13º 07' 34:82", *រយៈទទឹង*(E) 103º 18' 56:75" *និងលេខកូដ* (ID No.) 020803 ។

# ខេត្តកំពង់ចាម

## ៨) គុកសន្តិសុខបាធាយ (វត្តបាធាយ)

*រោងប្រក់ហ៊ីប្រូស៊ីម៉ង់ត៍មួយត្រូវបានធ្វើឡើងនៅក្បែររណ្តៅជាច្រើន និងក្បែរអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ដើម្បីធ្វើជាកន្លែងដាក់តម្កល់អដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ សាក្សីជុំវិញកន្លែងកើតហេតុនិយាយថា ប្រជាជនបានគាស់សាកសពឡើង ដើម្បីជាភស្តុតាងបញ្ជាក់ពីការសម្លាប់មនុស្សរបស់ខ្មែរក្រហម និងដើម្បីជាការគោរពដល់វិញ្ញាណក្ខន្ធដល់អ្នកដែលបានចែកឋានទៅ ។ ឆ្អឹងលលាដ៏ក្បាលរាប់រយដែលភាគច្រើនជាឆ្អឹងដែលបែក ត្រូវប្រជាជនស្រង់ចេញពីក្នុងរណ្តៅ រួចយកមកដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានដែលបានធ្វើនេះ ។*

***អ្នកផ្តល់ព័ត៌មានៈ***

*ឆាយ ឡឹង អាយុ៨៥ឆ្នាំ ភេទប្រុស រស់នៅភូមិព្រៃញរ ឃុំសន្ទរ ស្រុកបាធាយ ខេត្តកំពង់ចាម ។*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់*(N) 11º 5-9' 45:51", *រយៈទទឹង*(E) 104º 56' 47:80" *និងលេខកូដ* (ID No.) 030101 ។

## ៩) វត្តពះព្រាង

*រហូតមកដល់បច្ចុប្បន្ននេះ អដ្ឋិធាតុដែលដាក់តម្កល់នៅវត្តពព្រេងបានត្រូវបំផ្លាញទាំងស្រុង ។ វត្តពព្រេងស្ថិតនៅក្នុងភូមិវាល ឃុំស្ទឹង ស្រុកចំការលើ ខេត្តកំពង់ចាម ។ តាមចម្លើយរបស់ កង ឌុំ បានបង្ហាញថា អដ្ឋិធាតុដែលប្រជាជនគាស់ចេញពីទីតាំងសម្លាប់ត្រពាំងខ្នារ ហើយជញ្ជូនមកដាក់នៅក្នុងវត្ត*

ពព្រេងនេះ គឺដើម្បីទុកជាការគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់ដោយអំពើអយុត្តិធម៌ក្នុងរបបខ្មែរក្រហម ។

**អ្នកផ្តល់ព័ត៌មានៈ**

១) ឡុង ខេង រស់នៅភូមិពព្រេង ឃុំស្ទឹង ស្រុកចម្ការលើ ខេត្តកំពង់ចាម ។

២) កង ខុំ រស់នៅភូមិពព្រេង ឃុំស្ទឹង ស្រុកចម្ការលើ ខេត្តកំពង់ចាម ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 20' 35:88", រយៈទទឹង(E) 105º 19' 48:15" និងលេខកូដ (ID No.) 030203 ។

## ១០) វត្តស្គន់

ចេតិយ៍ដ៏ថ្មីសន្លាងមួយនៅក្នុងវត្តស្គន់ ដែលសាងសង់ឡើងដោយក្រុមសាច់ញាតិរបស់សាកសព គឺដើម្បីធ្វើជាវិមានរំឭកវិញ្ញាណក្ខន្ធចំពោះជនរងគ្រោះដែលត្រូវបានសម្លាប់នៅទីតាំងសម្លាប់មនុស្សនៅក្បែរនោះ ។ មានតែឆ្អឹងក្បាប៉ុណ្ណោះ ដែលត្រូវបានរៀបដាក់ជាជុង ជាធ្នឹម មានបែបបទជាបួនជ្រុង ទំហំ២ម៉ែត្រក្រឡា ដែលអាចបញ្ជាក់បានថា មានចំនួនជាច្រើនពាន់នាក់ ។ ក្នុងរយៈចម្ងាយប្រហែល៥០០ម៉ែត្រខាងលិចវត្ត គឺជាទីតាំងសម្លាប់មនុស្សដ៏ធំមួយដែលមានរណ្តៅសាកសពជាច្រើន ប៉ុន្តែឥឡូវបានប្រែក្លាយទៅជាចម្ការស្វាយចន្ទី ។ វត្តស្គន់ ស្ថិតនៅភូមិស្គន់ ឃុំសូទេព ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។

**អ្នកផ្តល់ព័ត៌មានៈ**

ជិត ជឿន រស់នៅភូមិស្គន់ ឃុំសូទេព ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 03' 42", រយៈទទឹង(E) 105º 04' 20:05" និងលេខកូដ (ID No.) 030301 ។

## ១១) វត្តនគរ

វត្តនគរ ស្ថិតនៅភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ នៅក្នុងបរិវេណវត្តនគរ មានប្រាសាទបុរាណមួយសង់ឡើងផ្ទាល់ដី ដែលមានបែបផែនដូចជាប្រាសាទអង្គរដែរ ។ នៅក្នុងវត្តនេះមានមន្ទីរបូជនីយដ្ឋាន២កន្លែងគឺ មួយសម្រាប់ដាក់តម្កល់ឆ្អឹងសាកសពជាបណ្តោះអាសន្នក្នុងផ្ទះធ្វើពីបេតុង និងមួយទៀតជាចេតិយ៍ដែលដាក់តម្កល់ឆ្អឹងទុកសម្រាប់ធ្វើពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធ ។ ឆ្អឹងសាកសពដែលត្រូវបានយកមកដាក់តម្កល់ក្នុងចេតិយ៍ទាំងពីរនេះ គឺជាឆ្អឹងសាកសពមួយចំនួនត្រូវបាននាំមកពីរណ្តៅសាកសពវត្តភ្នំប្រុសដែលមានចម្ងាយ៨គីឡូម៉ែត្រពីវត្តនេះ តាមបណ្តោយផ្លូវជាតិជាតិលេខ៧ឆ្ពោះទៅក្រុងភ្នំពេញ ។ សារមន្ទីរទាំងនេះបានតម្កល់អដ្ឋិធាតុសាកសពចំនួនជាង១០០០នាក់ ។

**អ្នកផ្តល់ពត៌មានៈ** គ្មាន

**ទិន្នន័យកុំព្យូទ័រៈ** រយៈកម្ពស់(N) 12º 00' 03", រយៈទទឹង(E) 105º 26' 23" និងលេខកូដ (ID No.) 030601 ។

### ១២) វត្តភ្នំប្រុស

រណ្តៅសាកសពធំៗចំនួន៨៧រណ្តៅនៅជុំវិញវត្តភ្នំប្រុស ត្រូវប្រជាជនគាស់ឡើងនៅអំឡុងឆ្នាំ១៩៨០ ក្នុងគោលបំណងស្វែងរកមាស និងសមាជិកគ្រួសារដែលបានត្រូវសម្លាប់ដោយខ្មែរក្រហម ។ ឆ្អឹងដែលស្ថិតនៅរាយប៉ាយលើមាត់រណ្តៅដោយសារការគាស់នេះ ត្រូវបានប្រមូលមកដាក់នៅក្នុងអគារចាស់មួយដែលពីមុនជាផ្ទះបាយប្រចាំវត្តភ្នំប្រុស ។ ប៉ុន្តែដោយមានការរំខានពីអ្នកទៅមើល ឆ្អឹងមួយចំនួនធំក៏ត្រូវបានដឹកជញ្ជូនទៅកាន់វត្តនគរវិញ ។

**អ្នកផ្តល់ពត៌មានៈ**

វង់ សុផានី អាយុ៣៨ឆ្នាំ ភេទស្រី រស់នៅភូមិធាងជួង ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 01' 42", រយៈទទឹង(E) 105º 24' 59" និងលេខកូដ (ID No.) 030602 ។

### ១៣) វត្តអូរត្រកួន

វិមានរំឭកវិញ្ញាណក្ខន្ធថ្មីមួយ ត្រូវបានធ្វើឡើងនៅក្នុងបរិវេណវត្តអូរត្រកួនកាលពីខែឧសភា ឆ្នាំ ១៩៩២ ដើម្បីដាក់តម្កល់អដ្ឋិធាតុដែលគាស់ចេញពីរណ្តៅមួយចំនួនក្នុងចំណោមរណ្តៅទាំង៤៦៧ ។ យោងតាមឯកសារដែលទទួលបានសាលាស្រុកកងមាសបានឲ្យដឹងថា ចំនួនសាកសពដែលត្រូវខ្មែរក្រហមសម្លាប់ គឺមានរហូតដល់ទៅ៣២,៦៩០នាក់ឯណោះ ។ ក្នុងចំនួនសាកសពទាំងនេះ ភាគច្រើនជាប្រជាជនជម្លៀសពីទីក្រុងភ្នំពេញ ។ មានអដ្ឋិធាតុតិចតួចណាស់ដែលមាននៅក្នុងវិមានតម្កល់អដ្ឋិធាតុថ្មីនេះនាពេលបច្ចុប្បន្ន ។

**អ្នកផ្តល់ពត៌មានៈ** គ្មាន ។

**ទិន្នន័យកុំព្យូទ័រៈ** រយៈកម្ពស់(N) 11º 57' 01", រយៈទទឹង(E) 105º 14' 58" និងលេខកូដ (ID No.) 030703 ។

### ១៤) វត្តជីហែរ

វត្តជីហែរ ស្ថិតនៅភូមិជីហែរ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ អដ្ឋិធាតុជនរងគ្រោះដែលដាក់តម្កល់នៅទីតាំងអ្នកតាចិន ត្រូវប្រជាជនដឹកជញ្ជូនចេញតាមរទេះគោមកកាន់វត្តជីហែរ ។ អដ្ឋិធាតុទាំងនោះ ត្រូវប្រជាជនប្រមូលដាក់ក្នុងពាងចំនួន៤ រួចកប់ដីនៅក្នុងបរិវេណវត្តជីហែរ ។ ស៊ិន ណៃស៊ីន បានប្រាប់ពីមូលហេតុនៃការជញ្ជូនអដ្ឋិធាតុចេញពីទីតាំងអ្នកតាចិនថា មកពីមានការស្នើសុំទីតាំង

នេះធ្វើជាទីតាំងអ្នកតាចិនដូចដើមវិញពីសមាគមចិននៅក្នុងស្រុកកោះសូទិនកាលពីឆ្នាំ១៩៩៣ ។ មួក សារិន និងអ៊ីង ខេមរា បានប្រាប់ថា អដ្ឋិធាតុជនរងគ្រោះទាំងនោះ គឺត្រូវបានគាស់ចេញពីរណ្ដៅជាច្រើននៅជុំវិញទីតាំងសម្លាប់វត្តជំនីក ។

**អ្នកផ្ដល់ព័ត៌មានៈ**

១) មួក សារិន ភេទប្រុស ជាបុគ្គលិកការិយាល័យសាលាស្រុកកោះសូទិន ខេត្តកំពង់ចាម ។

២) ចាន់ គឹមជិន ជាប្រធានការិយាល័យវប្បធម៌ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

៣) ចាន់ គឹមជិន ភេទប្រុស រស់នៅភូមិផ្សារថ្មី ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 11º 53' 39:98", រយៈទទឹង(E) 105º 25' 58:66" និងលេខកូដ (ID No.) 030803 ។

## ១៥) វត្តចាស់ (វត្តក្អោកចាស់)

មន្ទីរបូជនីយដ្ឋានដែលត្រូវបានសាងសង់នៅក្នុងបរិវេណវត្តចាស់(វត្តក្អោកចាស់) ត្រូវបានរុះរើជាមួយនឹងទីវត្តទាំងមូល នៅពេលដែលវត្តនេះត្រូវបានផ្លាស់ប្ដូរទីតាំងថ្មីទៅកាន់កន្លែងផ្សេងមួយទៀត ។ អដ្ឋិធាតុដែលមាននៅក្នុងមន្ទីរបូជនីយដ្ឋានទាំងអស់ ត្រូវលោកអាចារ្យ និងដូនជីជីកកប់ទៅក្នុងដីនាកន្លែងដដែលវិញ ខណៈពេលដែលមន្ទីរបូជនីយដ្ឋាននេះត្រូវរុះរើ ។

**អ្នកផ្ដល់ព័ត៌មានៈ**

១) បូ ទ្រី ភេទប្រុស អាយុ៨២ឆ្នាំ ជាប្រធានភូមិក្អោក ឃុំគគីរ ស្រុកមេមត់ ខេត្តកំពង់ចាម ។

២) គ្រុយ ឡេង ភេទប្រុស អាយុ៥១ ជាប្រធានឃុំគគីរ ស្រុកមេមត់ ខេត្តកំពង់ចាម ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 11º 54' 08:10", រយៈទទឹង(E) 106º 04' 95:88" និងលេខកូដ (ID No.) 031003 ។

## ១៦) ព្រៃធូរដុង

អដ្ឋិធាតុដែលប្រមូលបានក្រោយការគាស់រណ្ដៅសាកសពនៅព្រៃធូរដុង ត្រូវប្រជាជនប្រមូលមកដាក់ក្នុងកន្លែងតែមួយ គឺនៅក្នុងចេតិយ៍មួយក្នុងទីធ្លាវត្តអូររាំងឪ ។ ព្រៃធូរដុងមានទីតាំងស្ថិតនៅភូមិលេខ២ ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ។ ជីវ ហ៊ាន់ អាយុ៦៨ឆ្នាំ រស់នៅភូមិលេខ១ ឃុំគងជ័យ បានប្រាប់ថា ព្រៃធូរដុងជាទីតាំងសម្លាប់មនុស្ស និងមន្ទីរឃុំឃាំងបណ្ដោះអាសន្នរបស់ខ្មែរក្រហម ។ ជនរងគ្រោះដែលបានស្លាប់ និងសម្លាប់ស្ទើរតែទាំងអស់នៅទីនេះ គឺជាប្រជាជន១៧មេសា ។

**អ្នកផ្ដល់ព័ត៌មានៈ**

១) ជីវ ហ៊ន់ អាយុ៦៨ឆ្នាំ រស់នៅភូមិលេខ១ ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ។

២) ឯម យិន មន្ត្រីការិយាល័យវប្បធម៌ស្រុកអូររាំងឪ ។

*ទិន្នន័យកុំព្យូទ័រៈ*

រយៈកម្ពស់(N) 11º 47' 38:24", រយៈទទឹង(E) 105º 30' 26:22" និងលេខកូដ (ID No.) 031101 ។

## ១៧) វត្តជ័យមង្គល

បរិវេណវត្តជ័យមង្គល គឺជាអតីតមន្ទីរសន្តិសុខ និងកន្លែងសម្លាប់របស់ខ្មែរក្រហម ។ ក្រោយឆ្នាំ ១៩៧៩ រណ្ដៅជាច្រើនត្រូវបានគាស់ ហើយអដ្ឋិធាតុដែលនៅរាយប៉ាយក៏ត្រូវប្រជាជនប្រមូលយកមក ដាក់នៅក្នុងមន្ទីរបូជនីយដ្ឋានមួយ ដែលសាងសង់ឡើងដើម្បីទុកជាការគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបាន ស្លាប់ទៅ ។ តាមសម្ដីអ្នកភូមិបានឲ្យដឹងថា ជនរងគ្រោះត្រូវបានសម្លាប់ច្រើនបំផុតនៅចុងឆ្នាំ១៩៧៨ ។

*អ្នកផ្ដល់ព័ត៌មានៈ* គ្មាន

*ទិន្នន័យកុំព្យូទ័រៈ* រយៈកម្ពស់(N) 11º 54' 17", រយៈទទឹង(E) 105º 14' 37" និងលេខកូដ (ID No.) 031403 ។

## ១៨) វត្តស្ទឹងត្រង់

វត្តស្ទឹងត្រង់ ស្ថិតនៅក្នុងភូមិព្រៃបារាំង ឃុំព្រែកកោះ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ កាលពី ឆ្នាំ១៩៩៥ ក្រុមស្រាវជ្រាវត្រូវបានជូនដំណើរទៅកាន់ក្រោយវត្តនេះ ហើយត្រូវបានបង្ហាញឲ្យឃើញ មន្ទីរបូជនីយដ្ឋានបាក់បែកមួយដែលសង់អំពីឈើ ។ បំណែកឈើបាក់បែកនៃមន្ទីរបូជនីយដ្ឋាននេះ បានដួល រលំលើលលាដ៏ក្បាល និងឆ្អឹងសាកសពរាប់រយ ហើយព្រៃស្បាតបានដុះគ្របដណ្ដប់ពីលើពំនូកឆ្អឹងនោះ ទៀតផង ។ នៅជិតនោះដែរ មានរណ្ដៅសាកសពជាង២០រណ្ដៅ ព្រមទាំងមានសេសសល់បំណែកឆ្អឹង និងចំរៀកខោអាវរបស់សាកសពនៅក្បែរនោះផង ។ ព្រះវិហារក្នុងវត្តស្ទឹងត្រង់ ប្រហែលជាត្រូវបានប្រើ ធ្វើជាមន្ទីរឃុំឃាំងសម្រាប់អ្នកទោសដែលត្រូវបានសម្លាប់នៅទីតាំងសម្លាប់ក្រោយវត្តនេះ ។

*អ្នកផ្ដល់ព័ត៌មានៈ* គ្មាន

*ទិន្នន័យកុំព្យូទ័រៈ* រយៈកម្ពស់(N) 12º 15' 17", រយៈទទឹង(E) 105º 32' 02" និងលេខកូដ (ID No.) 031501 ។

## ១៩) ចម្ការស្វាយ

ចម្ការស្វាយ ជាអតីតមន្ទីរឃុំឃាំង និងកន្លែងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ រណ្ដៅសាកសព ដែលមានទីតាំងនៅប៉ែកខាងជើងឃុំសួង ត្រូវបានគាស់ឡើង ហើយអដ្ឋិធាតុជនរងគ្រោះត្រូវបានគរទុកនៅ ក្បែរនោះជាបណ្ដោះអាសន្នសិន ។ មន្ទីរឃុំឃាំងត្រូវបានសង់ឡើងពីឈើ និងស្លឹកត្នោត ហើយមានអណ្ដូង

*ជ្រៅៗពីរកន្លែង និងរណ្ដៅសាកសព១៥រណ្ដៅ ដែលត្រូវបានប្រើធ្វើជាកន្លែងសម្ងាប់ និងកប់សាកសព នៅជិតមន្ទីរឃុំឃាំងនោះ ។ ជនរងគ្រោះទាំងអស់គឺជាទាហានរបស់ លន់ ណុល និងប្រជាជនថ្មី ។*

***អ្នកផ្ដល់ព័ត៌មានៈ*** *គ្មាន*

***ទិន្នន័យកុំព្យូទ័រៈ*** *រយៈកម្ពស់*(N) 11º 56' 03", *រយៈទទឹង*(E) 105º 39' 48" *និងលេខកូដ* (ID No.) 031601 ។

## ២០) វត្តវិហារទន្ទឹម

*មន្ទីរបូជនីយដ្ឋាននៅក្នុងវត្តវិហារទន្ទឹម មានតម្កល់អដ្ឋិធាតុដែលប្រជាជនបានគាស់ចេញពីរណ្ដៅសាកសពនៅទីតាំងចំការស្វាយ និងចំការម្នាស់ ។ នៅទីនេះយើងបានសម្ភាសន៍សាក្សីម្នាក់កាលពីឆ្នាំ ១៩៩៥ឈ្មោះ វ៉ា ដា ព្រោះគាត់ធ្លាប់បានឃើញសាកសពរបស់ សោ ភឹម ក្រោយពេលដែលសាកសពនោះត្រូវបាននាំមកកាន់ឃុំសួងដោយរថក្រោះក្នុងឆ្នាំ១៩៧៨ ។ គាត់បានរាយការណ៍ថា សាកសពត្រូវបានដាក់តាំងនៅក្នុងហិបឈើចំហរគ្របមួយនៅក្នុងផ្សារ ហើយបន្ទាប់មកសាកសពនេះត្រូវបាននាំយកទៅកាន់ភ្នំពេញ ។*

***អ្នកផ្ដល់ព័ត៌មានៈ***

*វ៉ា ដា រស់នៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់*(N) 11º 54' 46", *រយៈទទឹង*(E) 105º 39' 19" *និងលេខកូដ* (ID No.) 031603 ។

# ខេត្តកំពង់ឆ្នាំង

## ២១) វត្តសម្ដេចមុនី

*បរិវេណជុំវិញវត្តសម្ដេចមុនី គឺជាអតីតទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ ទីតាំងទាំងនោះគឺ ព្រៃគោកល្វា ព្រៃគោកជ្រវត់ ភូមិត្នោតជោ (ភូមិចាស់) ព្រៃពោធិតាវ៉ា ព្រៃពោធិចារ្យ ព្រៃពោធិតាមឿន ព្រៃពោធិតាកុយ និងព្រៃតាន័យ ហៅព្រៃខ្មោច ។ ចំណែកក្នុងបរិវេណវត្តគឺជាមន្ទីរសន្តិសុខ ។ ក្រោយឆ្នាំ១៩៧៩ រណ្ដៅខ្លះត្រូវបានគាស់ ហើយអដ្ឋិធាតុត្រូវបានជញ្ជូនមកដាក់នៅមន្ទីរបូជនីយដ្ឋានមួយដែលសាងសង់ឡើងនៅក្នុងបរិវេណវត្តសម្ដេចមុនី ។*

***អ្នកផ្ដល់ព័ត៌មានៈ***

*ស៊ិន ង៉ាន់ អាយុ៧៣ឆ្នាំ ភេទប្រុស ជាគណៈកម្មការវត្តសម្តេចមុនី រស់នៅភូមិដក់ពរ ឃុំខ្នុរវ៉ែង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ។*

***ទិន្នន័យកុំព្យូទ័រ៖***

*រយៈកម្ពស់*(N) 12º 26' 18", *រយៈទទឹង*(E) 104º 28' 23:30" *និងលេខកូដ* (ID No.) 040101 ។

## ២២) វត្តខ្សាម

*មន្ទីរបូជនីយដ្ឋានវត្តខ្សាម ស្ថិតនៅខាងលិចសាលាខេត្តកំពង់ឆ្នាំងប្រហែល៥០០ម៉ែត្រ គឺនៅក្នុងវត្តខ្សាម ភូមិខ្សាម ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ អដ្ឋិធាតុត្រូវបានរក្សាទុកក្នុងចេតិយ៍មួយស្ថិតនៅខាងមុខព្រះវិហារ ដែលបច្ចុប្បន្ននៅសល់លលាដ៏ក្បាលប្រហែល១៣០ប៉ុណ្ណោះ ។ សួស សុផល ជាប្រធានមន្ទីរធម្មការខេត្ត រស់នៅភូមិដំណាក់អំពូល ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង បានរាយការណ៍នៅឆ្នាំ១៩៨២ថា គាត់ជាអ្នកដឹកជញ្ជូនអដ្ឋិធាតុចំនួន១៥០០ ជាមួយប្រជាជនផ្សេងទៀត មកដាក់តម្កល់នៅក្នុងបូជនីយដ្ឋានវត្តខ្សាម ។ រហូតមកដល់បច្ចុប្បន្ន អដ្ឋិធាតុភាគច្រើនត្រូវបានបំផ្លាញ និងបាត់បង់ ។*

***អ្នកផ្តល់ពត៌មាន៖***

*សួស សុផល បច្ចុប្បន្នជាប្រធានមន្ទីរធម្មការខេត្ត មានទីលំនៅភូមិដំណាក់អំពូល ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។*

***ទិន្នន័យកុំព្យូទ័រ៖***

*រយៈកម្ពស់*(N) 12º 15' 43:05", *រយៈទទឹង*(E) 104º 39' 75:19" *និងលេខកូដ* (ID No.) 040301 ។

## ២៣) វត្តចំប៉ី

*មន្ទីរបូជនីយដ្ឋានវត្តចំប៉ី ស្ថិតនៅក្នុងវត្តចំប៉ី ភូមិប្រមុះជ្រូក ឃុំជ្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ អដ្ឋិធាតុដែលប្រជាជនប្រមូលមកពីរណ្តៅសាកសពនៅទួលតាកន និងវាលថ្កូវ ត្រូវយកមកដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋាននេះ ។ ពៅ ផន ជាប្រធានឃុំជ្រេស បាននិយាយថា អដ្ឋិធាតុខ្លះត្រូវប្រជាជននាំយកមកពីទីតាំងសម្លាប់វត្តចំប៉ា និងកន្លែងផ្សេងទៀត មកដាក់នៅក្នុងមន្ទីរបូជនីយដ្ឋានវត្តចំប៉ី ។ មកដល់ពេលនេះ អដ្ឋិធាតុមួយចំនួនបានបាត់បង់ ។ ឯចំនួនដែលនៅសល់លើធ្នើនៃបូជនីយដ្ឋាន ហាក់ពុំមានការថែទាំឲ្យបានដិតដល់ដែរ ។*

***អ្នកផ្តល់ពត៌មាន៖***

*១) ពៅ ផន ជាប្រធានឃុំជ្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។*

*២) ទេព ហឿន ភេទប្រុស រស់នៅភូមិចក ឃុំជ្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។*

៣) ស៊ិន ស៊ុន ភេទស្រី រស់នៅភូមិចក ឃុំជ្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 11º 56' 96:36", រយៈទទឹង(E) 104º 45' 68:91" និងលេខកូដ (ID No.) 040501 ។

## ២៤) បន្ទាយចាស់

នៅក្នុងភូមិស្រែតាជ័យ មន្ទីរបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះសម័យខ្មែរក្រហមមួយ បានត្រូវបង្កើតឡើងនៅក្បែររណ្ដៅសាកសពជាច្រើនក្នុងទីតាំងសម្លាប់បន្ទាយចាស់ ។ អដ្ឋិធាតុដែលយកមកពីរណ្ដៅសាកសពបន្ទាយចាស់ ពីមន្ទីរសន្តិសុខសុវណ្ណ និងពីខាងមុខសាលាស្រុកទឹកផុស ត្រូវយកមកដាក់តម្កល់នៅក្នុងបូជនីយដ្ឋាននេះទាំងអស់ ។

**អ្នកផ្ដល់ពត៌មានៈ**

១) គី សុងឆាយ ភេទប្រុស អាយុ៤៣ឆ្នាំ ជាប្រធានការិយាល័យវប្បធម៌ស្រុកទឹកផុស ។

២) ជា គឹមលន់ ភេទប្រុស អាយុ៤៩ឆ្នាំ ជាអនុប្រធានការិយាល័យវប្បធម៌ស្រុកទឹកផុស ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 03' 02:61", រយៈទទឹង(E) 104º 31' 26:92" និងលេខកូដ (ID No.) 040803 ។

# ខេត្តកំពង់ស្ពឺ

## ២៥) វត្តបរសេដ្ឋចាស់

ចេតីយ៍មួយនៅវត្តបរសេដ្ឋចាស់ ត្រូវបានយកធ្វើជាកន្លែងដាក់អដ្ឋិធាតុជនរងគ្រោះដែលត្រូវខ្មែរក្រហមសម្លាប់នៅភូមិខ្នឹប ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។ នៅពេលក្រោយមកទៀត អាជ្ញាធរស្រុកបរសេដ្ឋបានដឹកជញ្ជូនអដ្ឋិធាតុមួយចំនួនធំយកទៅថែរក្សាទុកនៅកន្លែងផ្សេង ។ នៅឆ្នាំ១៩៩៧ ចេតីយ៍នេះត្រូវបានជួសជុលឡើងវិញ ។ អដ្ឋិធាតុដែលនៅសល់ក្នុងចេតីយ៍នេះ មិនត្រូវបានទទួលការយកចិត្តទុកដាក់ថែទាំឡើយ ។ កម្ទេចកម្ទីរខោអាវ និងឆ្អឹងដែលមាននៅក្នុងចេតីយ៍ ត្រូវពុកផុយស្ទើរគ្មានសល់ ។ សម្រាមផ្សេងៗត្រូវបានបោះគរពីលើឆ្អឹងទាំងនោះ ។

**អ្នកផ្ដល់ពត៌មានៈ**

១) អ៊ូ ណាន់ អាយុ៦០ឆ្នាំ រស់នៅភូមិស្រែគ្រោត ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

២) កុយ សៅ អាយុ៧២ឆ្នាំ រស់នៅភូមិចម្ការទួល ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

៣) ចាន់ ឈុំ អាយុ៤៩ឆ្នាំ រស់នៅភូមិចម្ការទួល ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់*(N) 11º 09' 13:24", *រយៈទទឹង*(E) 104º 31' 33:86" *និងលេខកូដ* (ID No.) 050105 ។

## ២៦) វត្តអំពែភ្នំ

*នៅប៉ែកខាងត្បូងឈៀងខាងលិចវត្តអំពែភ្នំប្រហែល២០០ម៉ែត្រ មន្ទីរបូជនីយដ្ឋានមួយបានត្រូវសាងសង់ឡើង ដើម្បីដាក់តម្កល់អដ្ឋិធាតុដែលបានគាស់ចេញពីរណ្តៅមួយចំនួនដែលស្ថិតនៅជុំវិញបរិវេណវត្ត និងពីទីតាំងសម្លាប់បន្ទាយរោងគោ ។ នៅឆ្នាំ១៩៨៦ ការសាងសង់បានចាប់ផ្តើមឡើង ។ ថវិកាឧបត្ថមការសាងសង់នេះ គឺបានមកពីការរៃអង្គៀសថវិកាពីវត្តនានា និងប្រជាជនក្នុងស្រុក ។ មន្ទីរនេះមានទំហំប្រហែល៥ម៉ែត្រក្រឡា មានដំបូលប្រក់ក្បឿងនិងពាសជញ្ជាំងក្តារ ។ ប៉ុន្តែនាបច្ចុប្បន្ននេះ ជញ្ជាំងក្តារទាំងនោះត្រូវពុកផុយស្ទើរទាំងអស់ ។ នៅចំកណ្តាលមន្ទីរនេះ មានទម្រដាក់អដ្ឋិធាតុធំមួយដែលសព្វថ្ងៃនៅតែជាទម្រដ៏រឹងមាំដដែល ។ មានទម្រមួយទៀតដែលស្ថិតនៅចំពីលើពំនូកឆ្អឹង គឺជាទម្រសម្រាប់ដាក់សម្លៀកបំពាក់ជនរងគ្រោះដែលត្រូវបានសម្លាប់ដោយខ្មែរក្រហម ។ អដ្ឋិធាតុមួយចំនួន ទើបតែត្រូវនាំយកទៅដាក់គរជាមួយនឹងអដ្ឋិធាតុមុនៗ បន្ទាប់ពីប្រាំងស៊ីងត្រូវបាក់ស្រុតចូលទៅក្នុងស៊ីង ។ សាក្សីនិយាយថា មានឆ្អឹងច្រើនគួរសមបានលេចឡើងនៅពេលដែលប្រាំងស៊ីងបានបាក់ចុះ ។ មុនពេលចូលទៅដល់កន្លែងតម្កល់អដ្ឋិធាតុ ដំបូងគេដែលត្រូវឃើញគឺផ្លាកដែលសរសេរប្រាប់ពីចំនួនមនុស្សស្លាប់នៅបរិវេណវត្តអំពែភ្នំដែលត្រូវបានរាប់យ៉ាងយកចិត្តទុកដាក់ក្រោយពេលគាស់ និងមុនពេលដែលអដ្ឋិធាតុទាំងនេះ ត្រូវជញ្ជូនយកទៅដាក់តម្កល់នៅក្នុងបូជនីយដ្ឋាននេះ ។ រហូតមកដល់សព្វថ្ងៃ ថ្វីត្បិតតែមានការថែទាំយ៉ាងយកចិត្តទុកដាក់ចំពោះអដ្ឋិធាតុដែលមាននេះ ក៏នៅមានអដ្ឋិធាតុមួយចំនួនត្រូវបានលួច និងបាត់បង់ដែរ លើកលែងតែការស្នើសុំពីខាងគណៈកម្មការធ្វើកោសល្យវិច័យឆ្អឹងសាកសពជនរងគ្រោះ ចំពោះអាជ្ញាធរមូលដ្ឋានក្នុងការនាំយកឆ្អឹងលលាដ៏ក្បាលខ្លះមកដាក់តម្កល់ទុក សម្រាប់ធ្វើជាភស្តុតាងក្នុងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមនាពេលខាងមុខ ។*

*អ្នកផ្តល់ព័ត៌មានៈ*

*ចាន់ ម៉ៃ អាយុ៦៥ឆ្នាំ ភេទប្រុស រស់នៅភូមិអំពែភ្នំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។*

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់*(N) 11º 27' 11:29", *រយៈទទឹង*(E) 104º 32' 29:38" *និងលេខកូដ* (ID No.) 050201 ។

# ខេត្តកំពង់ធំ

## ២៧) វត្តបារាយជាន់ដែក

វត្តបារាយណ៍ជាន់ដែក ស្ថិតនៅក្នុងភូមិក្រោះ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ចេតិយ៍ដ៏ធំមួយដែលស្ថិតនៅក្នុងបរិវេណវត្តនេះ ត្រូវបានយកធ្វើជាកន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះ ។ ឆ្អឹងលលាដ៍ក្បាលជាច្រើន ត្រូវអាចារ្យវត្ត និងប្រជាជនរើសយកមកដាក់គរពីលើឆ្អឹងស្មង ដៃនិងស្មងជើងជាច្រើន ដែលបានដាក់តម្រៀបលើគ្នារហូតមានកម្ពស់ប្រហែលជាងមួយម៉ែត្រ ។ កំប៉ុងទឹកដោះគោដ៏កញ្ចាស់មួយ ដែលត្រូវបានប្រើប្រាស់ជាកំប៉ុងសម្រាប់អុជធូប កំពុងតែស្ថិតនៅពីមុខគំនរឆ្អឹងទាំងនោះ ។ ព្រះសង្ឃគណកម្មការវត្ត និងប្រជាជនចំណុះជើងវត្ត បានថែរក្សាអដ្ឋិធាតុទាំងនេះបានយ៉ាងត្រឹមត្រូវ ។

គិន សាង អាយុ៥១ឆ្នាំ រស់នៅភូមិក្រោម ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ បាននិយាយថា អដ្ឋិធាតុទាំងនេះគឺបានគាស់ចេញពីរណ្តៅជិត២០០នៅមុខព្រះវិហារ ព្រមទាំងសន្និដ្ឋានថាមានជនរងគ្រោះស្លាប់ប្រមាណពី១៥,០០០ទៅ២០,០០០នាក់ ។

**អ្នកផ្តល់ពត៌មានៈ**

១) គិន សាង អាយុ៥១ឆ្នាំ រស់នៅភូមិក្រោម ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

២) គិន ហេង អាយុ៨៩ឆ្នាំ នៅភូមិក្រោម ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

៣) ស្រី ថាន់ អាយុ៣១ឆ្នាំ រស់នៅភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 29' 37:74", រយៈទទឹង(E) 105º 08' 11:29" និងលេខកូដ (ID No.) 060102 ។

## ២៨) វត្តទួល

ចេតិយ៍តូចល្មមមួយស្ថិតនៅពីមុខកុដិដែលជាអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ត្រូវប្រជាជនយកធ្វើជាមន្ទីរបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះដែលស្លាប់ក្នុងរបបខ្មែរក្រហម ។ មានអដ្ឋិធាតុមិនច្រើនប៉ុន្មានទេនៅក្នុងចេតិយ៍នេះ ហើយភាគច្រើនជាលលាដ៏ក្បាលដែលបែកជាបំណែកៗ ។ ចេតិយ៍មួយនេះមានទីតាំងស្ថិតនៅក្នុងបរិវេណវត្តទួល ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**អ្នកផ្តល់ពត៌មានៈ**

ស្រី ថាន់ អាយុ៣១ឆ្នាំ រស់នៅភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 23' 07:22", រយៈទទឹង(E) 105º 05' 30:06" និងលេខកូដ (ID No.) 060104 ។

## ២៩) វត្តភ្ញីជួង

ដោយអនុវត្តតាមគោលការណ៍របស់រដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រជាជននៅភូមិក្ដីដូង ឃុំក្ដីដូង ស្រុកស្ទឹងសែន ខេត្តកំពង់ធំ បានសាងសង់មន្ទីរបូជនីយដ្ឋានមួយនៅវត្តក្ដីដូង ដើម្បីតម្កល់អដ្ឋិធាតុជនរងគ្រោះដែលស្លាប់ជំនាន់ខ្មែរក្រហម ។ សាក្សីនិយាយថា អដ្ឋិធាតុដែលដាក់តម្កល់នៅក្នុងបូជនីយដ្ឋាននេះ សុទ្ធតែត្រូវបានគាស់ និងជញ្ជូនយកចេញពីអណ្ដូងទឹកចំនួនបួនកន្លែង ដែលមាននៅក្នុងភូមិក្ដីដូង និងយកមកពីគ្រប់កន្លែងក្នុងស្រុកស្ទឹងសែន ។

**អ្នកផ្ដល់ពត៌មានៈ**

យៀន ប៉ុង អាយុ៦២ឆ្នាំ រស់នៅភូមិ និងឃុំក្ដីដូង ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 43' 08:53", រយៈទទឹង(E) 104º 51' 27:85" និងលេខកូដ (ID No.) 060301 ។

## ៣០) វត្តសំបូរ

មន្ទីរបូជនីយដ្ឋានវត្តសំបូរ ឬវត្តប្រាសាទសំបូរ ត្រូវបានសាងសង់ឡើងស្រដៀងគ្នានឹងមន្ទីរបូជនីយដ្ឋានវត្តអំពែរភ្នំដែរ ប៉ុន្តែនៅទីនេះមានទំហំតូចជាងបន្តិច ហើយពុំមានឆ្អឹងតម្កល់ច្រើនដូចអំពែរភ្នំឡើយ ។ កាលពីឆ្នាំ១៩៩៨ នៅខាងក្នុងបូជនីយដ្ឋាននេះមានសេសសល់អដ្ឋិធាតុតែបន្តិចប៉ុណ្ណោះ មិនដូចពីមុនឡើយ ។ ទិត ថន អាយុ៤៥ឆ្នាំ ភេទប្រុស រស់នៅភូមិសេរីសុខា ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ បាននិយាយថា អដ្ឋិធាតុនេះត្រូវប្រជាជនប្រមូលមកពីទីតាំងសម្លាប់ក្រោយវត្ត និងប្រមូលមកពីទីតាំងផ្សេងៗទៀត ។

**អ្នកផ្ដល់ពត៌មានៈ**

១) ទិត ថន អាយុ៤៥ឆ្នាំ ភេទប្រុស រស់នៅភូមិសេរីសុខា ឃុំឈូក ស្រុកប្រាសាទសំបូរ ។

២) ស៊ាន ស៊ាងហោ ភេទប្រុស រស់នៅភូមិសេរីសុខា ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 12º 53' 0&:58", រយៈទទឹង(E) 105º 03' 54:50" និងលេខកូដ (ID No.) 060503 ។

## ៣១) វត្តតាំងក្រសាំង

អដ្ឋិធាតុជាច្រើនដែលត្រូវបានប្រមូលមកពីទីតាំងសម្លាប់នានាក្នុងស្រុកសន្ទុក ត្រូវជញ្ជូនយកមកដាក់នៅក្នុងចេតិយ៍មួយដែលសាងសង់ឡើងនៅក្នុងព្រៃគគីរនាវត្តតាំងក្រសាំង ។ គោលបំណងនៃការប្រមូលឆ្អឹងសាកសពមកដាក់នៅក្នុងចេតិយ៍នេះ គឺដើម្បីធ្វើជាកន្លែងប្រារព្ធទិវាថ្ងៃចងកំហឹងទី២០ ឧសភា

ជារៀងរាល់ឆ្នាំ ។ ឆ្អឹងលលាដ៍ក្បាល ត្រូវបានដាក់តម្រៀបគ្នាលើធ្នើធ្វើពីស៊ីម៉ង់ត៍ផុតពីដីក្នុងចេតិយ៍នេះ ។ វត្តតាំងក្រសាំង ស្ថិតនៅភូមិ និងឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។

*អ្នកផ្តល់ព័ត៌មានៈ*

ឡេង ណាវ អាយុ៦៥ឆ្នាំ រស់នៅភូមិសង្កមថ្មី ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធ ។

*ទិន្នន័យកុំព្យូទ័រៈ*

រយៈកម្ពស់ (N) 12º 33' 34:16", រយៈទទឹង (E) 105º 02' 56:71" និងលេខកូដ (ID No.) 060705 ។

## ៣២) ទួលគាគួច

មន្ទីរបូជនីយដ្ឋានដ៏ថ្មីមួយ ត្រូវបានប្រជាជននិងក្រុមគ្រួសារជនរងគ្រោះដែលបានស្លាប់នៅទីតាំងសម្លាប់ទួលគាភួង សហការគ្នាសាងសង់ឡើងនៅលើដីនាទីតាំងសម្លាប់តែម្តង ។ អដ្ឋិធាតុដែលបានគាស់ចេញពីរណ្តៅនៅជុំវិញមន្ទីរបូជនីយដ្ឋានទាំងអស់ ត្រូវប្រមូលយកមកដាក់តម្កល់នៅក្នុងមន្ទីរនេះ ។ លួន ខុម អាយុ៣៦ឆ្នាំ ភេទប្រុស រស់នៅភូមិត្រាច ឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ បាននិយាយថា មានសាកសពចំនួនប្រហែល៥០,០០០នាក់ ត្រូវបានគាស់ចេញពីរណ្តៅចំនួនពី២៥០ទៅ៥០០រណ្តៅ ហើយអដ្ឋិធាតុរបស់សាកសពទាំងនោះ ត្រូវបាននាំយកទៅដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានទួលគាភួង ដែលមានទីតាំងស្ថិតនៅក្នុងភូមិត្រាច ឃុំកំពង់ចិន ស្រុកស្ទោង ។

*អ្នកផ្តល់ព័ត៌មានៈ*

១) លួន ខុម អាយុ៣៦ឆ្នាំ ភេទប្រុស រស់នៅភូមិត្រាច ឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ ។

២) ហួត ហឿន រស់នៅភូមិត្រាច ឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ ។

៣) ជុំ វិន អាយុ៦០ឆ្នាំ ភេទប្រុស រស់នៅភូមិត្រាច ឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ ។

*ទិន្នន័យកុំព្យូទ័រៈ*

រយៈកម្ពស់ (N) 12º 57' 45:72", រយៈទទឹង (E) 104º 34' 06:55" និងលេខកូដ (ID No.) 060802 ។

# ខេត្តកំពត

## ៣៣) មន្ទីរតាម៉ន ១

មន្ទីរបូជនីយដ្ឋានធ្វើអំពីឈើដ៏ធំមួយស្ថិតនៅជិតទីតាំងសម្លាប់ និងមន្ទីរសន្តិសុខតាម៉ន ត្រូវបានសាងសង់ឡើងដើម្បីដាក់តម្កល់ឆ្អឹងលលាដ៍ក្បាល និងឆ្អឹងអវៈយវៈរាប់ពាន់ដែលត្រូវបានគាស់ចេញពីរណ្តៅចំនួន១៣៦កាលពីឆ្នាំ១៩៨២ ។ ជនរងគ្រោះទាំងអស់គឺជាប្រជាជនថ្មីដែលជម្លៀសពីក្រុងភ្នំពេញ និងស្ត្រី

ដែលជាអតីតប្រពន្ធមន្ត្រីនិងទាហាន លន់ នល់ ។ អិង សាភឿន គឺជាអ្នកទោសនៅក្នុងគុកស្ត្រីពីឆ្នាំ ១៩៧៧-៧៩ ព្រោះគាត់ជាភរិយារបស់មន្ត្រីថ្នាក់តូចម្នាក់នៅក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ហើយដែលបច្ចុប្បន្នគាត់រស់នៅភូមិតានី ។

*អ្នកផ្តល់ពត៌មានៈ*

អិង សាភឿន ភេទស្រី រស់នៅភូមិតានី ឃុំទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត ។

*ទិន្នន័យកុំព្យូទ័រៈ*

រយៈកម្ពស់ (N) 10º 36' 22", រយៈទទឹង (E) 104º 12' 18" និងលេខកូដ (ID No.) 070101 ។

## ៣៤) មន្ទីរតាម៉ន ២

នៅឆ្នាំ១៩៩៨ នៅពេលដែលក្រុមស្រាវជ្រាវចុះទៅធ្វើការនៅទីនោះម្តងទៀត យើងទទួលបានរបាយការណ៍ថា មន្ទីរបូជនីយដ្ឋានតាម៉នបានផ្លាស់ប្តូរទីតាំងថ្មី ជាមួយនឹងអគារថ្មីមួយធ្វើពីបេតុង និងទ្វារដែក ។ អដ្ឋិធាតុដែលមាននៅក្នុងមន្ទីរបូជនីយដ្ឋានចាស់ ត្រូវបានជញ្ជូនមកដាក់នៅកន្លែងថ្មីទាំងអស់ ។ មន្ទីរតាម៉ន មានទីតាំងស្ថិតនៅភូមិបុស្សរឹដុំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។ ក្រុមស្រាវជ្រាវបានកំណត់ទីតាំងភូមិសាស្ត្រថ្មីមួយទៀត តាមរយៈការប្រើប្រាស់ម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពិភពលោក (GPS) ។

*អ្នកផ្តល់ពត៌មានៈ*

ឌុក ជន់ អាយុ៧០ឆ្នាំ ភេទប្រុស រស់នៅភូមិបុស្សរឹដុំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។

*ទិន្នន័យកុំព្យូទ័រៈ*

រយៈកម្ពស់ (N) 10º 50' 57:96", រយៈទទឹង (E) 104º 39' 17:92" និងលេខកូដ (ID No.) 070102 ។

## ៣៥) វត្តស៊ឹង

វត្តស៊ឹង មានទីតាំងស្ថិតនៅភូមិស៊ឹង ឃុំឈូក ស្រុកឈូក ខេត្តកំពត ។ វត្តនេះមានមន្ទីរបូជនីយដ្ឋានមួយសង់អំពីឈើប្រក់ក្បឿង និងមានរចនាផ្ទាំលាបតាមចំរឹងជញ្ជាំងដែលធ្វើឡើងសម្រាប់ឲ្យមានខ្យល់អាកាសចេញចូលក្នុងកន្លែងតម្កល់ឆ្អឹងសាកសព ។ ទីនេះមានតម្កល់ឆ្អឹងសាកសពជនរងគ្រោះដែលបានស្លាប់កាលពីរបបខ្មែរក្រហមចំនួន៣២៥ ។ ឆ្អឹងលលាដ៏ក្បាលភាគច្រើន ជាឆ្អឹងបែកបាក់ និងពុកផុយ ។ កម្ទេចកម្ទីរខោអាវរបស់សាកសព និងខ្សែរជើងក៏ស្ថិតនៅលាយឡំជាមួយឆ្អឹងអវៈយវៈរបស់សាកសពដែរ ។

*អ្នកផ្តល់ពត៌មានៈ* គ្មាន

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់* (N) 10º 50' 36", *រយៈទទឹង* (E) 104º 27' 52.5" និង*លេខកូដ* (ID No.) 070301 ។

## ៣៦) វត្តជុំគ្រៀល

*វត្តជុំគ្រៀល ស្ថិតនៅក្នុងភូមិត្រពាំងធំ ឃុំជុំគ្រៀល ស្រុកកំពត ខេត្តកំពត ។ ចេតិយ៍សង់អំពីឈើមួយត្រូវបានសាងសង់សម្រាប់ដាក់តម្កល់អដ្ឋិធាតុជនរងគ្រោះ ដែលបានជីកជញ្ជូននាំមកពីរណ្តៅសាកសពក្នុងស្រុកកំពត ។ អដ្ឋិធាតុដែលបាននាំមកដាក់តម្កល់នៅទីនេះ ពុំមានចំនួនច្រើនប៉ុន្មានទេ ។ ខ្នោះជើងមួយចំនួន ក៏ត្រូវបានប្រមូលមកដាក់នៅក្នុងមន្ទីរបូជនីយដ្ឋាននេះដែរ ។*

***អ្នកផ្តល់ពត៌មានៈ*** គ្មាន

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់* (N) 10º 36' 22", *រយៈទទឹង* (E) 104º 12' 18" និង*លេខកូដ* (ID No.) 070701 ។

## ៣៧) វត្តកំពង់ត្រឡាច

*នៅតាមបណ្តោយផ្លូវឆ្ពោះទៅកាន់ភ្នំវល្លិ៍ ព្រះវិហារធ្វើពីស៊ីម៉ង់ត៍ដ៏ធំមួយនៅវត្តកំពង់ត្រឡាច ភូមិកំពង់ត្រឡាច ឃុំកែប ស្រុកកំពត ត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខកាលពីជំនាន់ខ្មែរក្រហម ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះ ត្រូវខ្មែរក្រហមនាំយកទោសម្លាប់នៅក្នុងរណ្តៅធំៗចំនួនពីរក្នុងបរិវេណវត្ត និងនៅកន្លែងផ្សេងទៀត ដែលមានចម្ងាយប្រហែល២គីឡូម៉ែត្រពីវត្ត ។ នៅឆ្នាំ១៩៧៩ រណ្តៅសាកសពទាំងនោះត្រូវបានគាស់ ហើយអដ្ឋិធាតុត្រូវនាំយកមកដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានមួយដែលសង់ផ្ទាល់ដីពីស៊ីម៉ង់ត៍ប្រក់ក្បឿងនាបរិវេណវត្តកំពង់ត្រឡាច ។ ណាត កែវ និយាយថា មានឆ្អឹងលលាដ៏ក្បាលទាំងអស់ចំនួន៧៥០ និងឆ្អឹងអវៈយវៈជាច្រើនទៀត ត្រូវបានប្រជាជនជីកជញ្ជូនមកកាន់មន្ទីរបូជនីយដ្ឋាននេះកាលពីឆ្នាំ១៩៧៩ ។*

***អ្នកផ្តល់ពត៌មានៈ*** គ្មាន

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់* (N) 10º 32' 47.5", *រយៈទទឹង* (E) 104º 18' 13" និង*លេខកូដ* (ID No.) 070702 ។

## ៣៨) វត្តពោធិ៍

---

[១] *បូកគោ, បើមេដឹកនាំខ្មែរក្រហមរួចផុតពីការកាត់ទោសគឺជាភាពអយុត្តិធម៌មួយសម្រាប់ជនរងគ្រោះ ។ ការសែតរស្មីកម្ពុជាៈ បោះពុម្ពនៅភ្នំពេញ ឆ្នាំទី១៤ លេខ៤០៣៥ ។*

មន្ទីរបូជនីយដ្ឋានដ៏កញ្ចាស់មួយដែលសង់ផុតពីដី មានជញ្ជាំងក្តារ និងដំបូលប្រក់ក្បឿង ស្ថិតនៅក្នុងបរិវេណវត្តពោធិ៍ ភូមិពោធិ៍ ឃុំថ្មី ស្រុកកំពត ខេត្តកំពត មានតម្កល់អដ្ឋិធាតុជនរងគ្រោះចំនួន៧៥នាក់ ។ គំនរឆ្អឹងដែលស្ថិតនៅចំកណ្តាលមន្ទីរបូជនីយដ្ឋាននាពេលបច្ចុប្បន្ននេះ ពុំមានការរៀបចំត្រឹមត្រូវឡើយ ហើយឆ្អឹងដែលនៅសេសសល់គឺជាឆ្អឹងលលាដ៏ក្បាល និងឆ្អឹងអវៈយវៈ ។ យោងតាមកាសែតរស្មីកម្ពុជាលេខ៤០៣៥ ចុះផ្សាយនៅថ្ងៃពុធ ទី១៩ ខែកក្កដា ឆ្នាំ២០០៦ បានឲ្យដឹងថា មន្ទីរបូជនីយដ្ឋានដ៏កញ្ចាស់មួយនេះ កំពុងត្រូវទទួលការគំរាមកំហែងពីបរិយាកាស ហើយអ្នកមើលការខុសត្រូវនៅទីនោះក៏កំពុងស្វែងរកជំនួយក្នុងការសាងសង់មន្ទីរបូជនីយដ្ឋានថ្មីមួយជំនួសដែរ ។ អ្នកយកពត៌មានរបស់កាសែតដដែលនេះបានស្រង់យកសម្តីរបស់លោកតា ហង្ស នួន អាយុ៦៨ឆ្នាំ ជាអាចារ្យវត្តពោធិ៍ថា មន្ទីរបូជនីយដ្ឋាននេះ បានសាងសង់ឡើងកាលពីឆ្នាំ១៩៨៣ បន្ទាប់ពីរណ្តៅសាកសពរួមមួយត្រូវបានគាស់ឡើងនៅក្នុងភូមិចិន ឃុំថ្មី ស្រុក និងខេត្តកំពត ។ សាកសពចំនួន៧៥នាក់ត្រូវបាននាំយកចេញពីរណ្តៅនោះទៅដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានដែលទើបនឹងសង់រួច ។ ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ន មន្ទីរបូជនីយដ្ឋាននេះក្លាយជារោងដែលទ្រុឌទ្រោម និងពុកផុយស្ទើរទាំងស្រុង ។

**អ្នកផ្តល់ពត៌មានៈ**

*ហង្ស នួន អាយុ៦៨ឆ្នាំ ជាអាចារ្យវត្តពោធិ៍ ។*

**ទិន្នន័យកុំព្យូទ័រៈ**

# ខេត្តកណ្តាល

## ៣៩ សាលាត្រពាំងស្វា

ផ្នែកមួយនៃមន្ទីរសន្តិសុខសាលាត្រពាំងស្វារបស់ខ្មែរក្រហម ដែលជាអតីតសាលាគរុកោសល្យ (វិក្រិតការ) បានត្រូវផ្លាស់ប្តូរទៅជាកន្លែងតំកល់អដ្ឋិធាតុដែលមានលលាដ៏ក្បាលមនុស្សរាប់ពាន់គរជាជង់ៗ ប្រហែលជាកំពស់២ម៉ែត្រ ។ មួយរយៈកាលក្រោយមក ដោយសារកង្វះការថែទាំ និងដោយសារសត្ពាហនៈស៊ីផង ឆ្អឹងមួយភាគត្រូវបានបំផ្លាញ និងបាត់បង់ ។ ដោយហេតុនេះហើយ ប្រជាជន និងអ្នកផ្តើមកសាងផ្សេងទៀត បានសហការគ្នាកសាងមន្ទីរបូជនីយដ្ឋានថ្មីមួយទៀត ដែលមានទីតាំងស្ថិតនៅប៉ែកខាងលិចអគារគុកដែលត្រូវបានប្រើប្រាស់ជាកន្លែងតម្កល់អដ្ឋិធាតុចាស់ ។ មន្ទីរបូជនីយដ្ឋានដែលធ្វើក្រោយនេះត្រូវបានប្រឌិតឡើងដោយការយកចិត្តទុកដាក់ខ្ពស់ ។ អដ្ឋិធាតុត្រូវបានបញ្ចូលទៅខាងក្នុង ហើយចាក់សោរពីក្រៅ ព្រមទាំងមានអ្នកយាមត្រឹមត្រូវផង ។

**អ្នកផ្តល់ពត៌មានៈ**

១) ឡុង ម៉េងគ្រី អាយុ៧១ឆ្នាំ ភេទប្រុស រស់នៅភូមិក្រាំងសម្បត្តិ ឃុំពុតសរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

២) សា សាំ អាយុ២៩ឆ្នាំ ជាអនុប្រធានភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

៣) សិរិត កុំ ភេទស្រី រស់នៅភូមិ និងឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

៤) គៅ សំអឿន ភេទស្រី រស់នៅភូមិ និងឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

៥) លី ឡាយហេង ភេទស្រី អាយុ៦២ឆ្នាំ រស់នៅភូមិក្រាំងសម្បត្តិ ឃុំពុតសរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

៦) សួស ម៉ៅ ភេទប្រុស អាយុ៥១ឆ្នាំ រស់នៅភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

៧) ដួន ឈុំ ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

៨) វ៉ាន់ ថុន ភេទប្រុស អាយុ៤៩ឆ្នាំ រស់នៅភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

**ទិន្នន័យកុំព្យូទ័រ**

រយៈកម្ពស់ (N) 11º 20' 59", រយៈទទឹង (E) 104º 49' 43" និងលេខកូដ (ID No.) 080101 ។

## ៤០) វត្តចំពុះក្អែក

រណ្តៅសាកសពជាច្រើននៅក្នុងវត្តចំពុះក្អែក ត្រូវបានគាស់កាលពីអំឡុងឆ្នាំ១៩៨០ ហើយឆ្អឹងលលាដ៏ក្បាល និងឆ្អឹងអវៈយវៈរាប់ពាន់ដែលគាស់បាន ត្រូវប្រជាជនដឹកយកទៅដាក់នៅបូជនីយដ្ឋានមួយកន្លែងស្ថិតនៅក្នុងបរិវេណវត្ត ។ មានខ្មោះឃ្មៀងជាច្រើន បានត្រូវដាក់ព្យួរតាមរបាជញ្ជាំងដែលធ្វើពីលួសសំណាញ់ព័ទ្ធជុំវិញអដ្ឋិធាតុ ។ នរណាក៏អាចមើលឃើញអដ្ឋិធាតុរាប់ពាន់នេះយ៉ាងច្បាស់ដែរ ។ កាលពីអំឡុងទសវត្សន៍ឆ្នាំ១៩៨០ សិស្ស និស្សិត លោកគ្រូ អ្នកគ្រូ បុគ្គលិកនៅតាម មន្ទីរជុំវិញស្រុកកៀនស្វាយ ព្រមទាំងប្រជាជន បានប្រារព្ធថ្ងៃចងកំហឹងចំពោះបនប្រល័យពូជសាសន៍ប៉ុលពត នៅរៀងរាល់ថ្ងៃទី២០ ខែឧសភា នៅក្នុងបរិវេណវត្តចំពុះក្អែកនេះ ។ ប៉ុន្តែឥឡូវ មិនដូចពីពេលមុនទេ ហើយចំនួនអដ្ឋិធាតុក៏មានការថយចុះដែរ ។

**អ្នកផ្តល់ព័ត៌មានៈ**

១) សាយ អ៊ុំ ភេទប្រុស អាយុ៦៨ឆ្នាំ រស់នៅភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

៧) ប៊ុន សឿន ភេទស្រី អាយុ៤០ឆ្នាំ រស់នៅភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 23' 58", រយៈទទឹង (E) 104º 57' 42" និងលេខកូដ (ID No.) 080203 ។

## ៤១) ពោធិ៍ធំន្លេ

ពោធិ៍ទន្លេ ជាកន្លែងឃុំឃាំងធំមួយប្រចាំស្រុកកោះធំ ដែលមានអ្នកទោសរាប់ពាន់នាក់ជាប់គុកនៅទីនោះ ។ ពោធិ៍ទន្លេជាកោះមួយស្ថិតនៅកណ្ដាលទន្លេនិងនៅក្នុងទឹកដីឃុំកោះធំ"ក" ស្រុកកោះធំ ខេត្តកណ្ដាល មានចម្ងាយ៥៨ គីឡូម៉ែត្រនៅភាគខាងត្បូងទីក្រុងភ្នំពេញតាមបណ្ដោយផ្លូវលេខ២១ ។

យ៉ែម ខុម អាយុ៦៧ឆ្នាំ ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខពោធិ៍ទន្លេកាលពីឆ្នាំ១៩៧៧ បានចំណាយពេលវេលាយ៉ាងច្រើនសម្រាប់ឧទ្ទិសកុសលផលបុណ្យជូនដល់វិញ្ញាណក្ខន្ធប្ដី និងកូនរបស់គាត់នៅកន្លែងដាក់តម្កល់អដ្ឋិធាតុជនរងគ្រោះពោធិ៍ទន្លេ ព្រោះប្ដីនិងកូនរបស់គាត់បានត្រូវសម្លាប់នៅទីនោះ ។ នៅឆ្នាំ១៩៩០ មន្ទីរបូជនីយដ្ឋានពោធិ៍ទន្លេ ត្រូវបានសាងសង់ឡើងក្រោមការជួយឧបត្ថម្ភពីលោកគួយ ស៊ីម លោកហ៊ត ផែ លោកឡុច សុផល ព្រះសង្ឃ និងពុទ្ធបរិស័ទជិតឆ្ងាយ ។ ឆ្អឹងលលាដ៍ក្បាល និងឆ្អឹងអវៈយវៈយ៉ាងច្រើនដែលគាស់ចេញពីរណ្ដៅចំនួន៩៥នៅក្បែរនោះ បានត្រូវដឹកជញ្ជូនមកដាក់តម្កល់ជាដុងៗនៅក្នុងមន្ទីរបូជនីយដ្ឋាន ។ តាមការប៉ាន់ស្មានជនរងគ្រោះដែលស្លាប់ នៅក្នុងបរិវេណពោធិ៍ទន្លេនេះ មានចំនួនប្រហែល៣៥,០២៧នាក់ ។ ឯការធ្វើបុណ្យឧទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទៅនៅទីតាំងពោធិ៍ទន្លេនេះ បានកើតឡើងស្ទើរតែរាល់ឆ្នាំ ។ រហូតមកដល់សព្វថ្ងៃ ប្រជាជនកម្ពុជាទូទៅ នៅតែអាចមើលឃើញមន្ទីរបូជនីយដ្ឋាននេះយ៉ាងច្បាស់ក្រឡែត និងអាចទៅមើលដោយផ្ទាល់បាន ។

**អ្នកផ្ដល់ព័ត៌មានៈ**

យ៉ែម ខុន អាយុ៦៨ឆ្នាំ រស់នៅភូមិកំពង់ស្វាយ ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 09' 04", រយៈទទឹង (E) 105º 04' 02" និងលេខកូដ (ID No.) 080402 ។

## ៤២) វត្តព្រែកដាច់

នៅឆ្នាំ១៩៨២ រណ្ដៅចំនួនប្រហែល៥៦រណ្ដៅស្ថិតនៅជុំវិញបរិវេណវត្តព្រែកដាច់ ត្រូវបានគាស់ដោយប្រជាជនក្នុងភូមិ ក្រោមការអង្កេតពីរដ្ឋាភិបាលកម្ពុជានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ឆ្អឹងដែលគាស់បានត្រូវដឹកជញ្ជូនយកទៅដាក់នៅមន្ទីរបូជនីយដ្ឋានមួយ ដែលសាងសង់ឡើងនៅលើទីតាំងដែលជាអតីត

មន្ទីរសន្តិសុខ១៨ ឬមន្ទីរសន្តិសុខព្រែកដាច់ ។ នៅពេលដែលក្រុមស្រាវជ្រាវចុះមកដល់ទីតាំងផ្ទាល់នៅវត្តព្រែកដាច់កាលពីដើមឆ្នាំ១៩៩៦ ចំនួនអដ្ឋិធាតុបានបាត់បង់អស់មួយភាគធំទៅហើយ ។

**អ្នកផ្តល់ព័ត៌មានៈ**

១) កែ កែប អាយុ៥០ឆ្នាំ ភេទប្រុស នៅភូមិលេខ១ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល ។

២) តាង តេង រស់នៅភូមិព្រែកដាច់ ឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 10' 18", រយៈទទឹង (E) 105º 13' 49.5" និងលេខកូដ (ID No.) 080503 ។

## ៤៣) វត្តរការកោង

វត្តរការកោង ឬវត្តជងទង់ ឬវត្តកែវមុនីជោតិ ស្ថិតនៅក្នុងភូមិរការកោង ឃុំរការកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ។ ថុន ថុល អាយុ៤០ឆ្នាំ និយាយថា នៅពេលដែលច្រាំងទន្លេបាក់ស្រុតចុះទៅក្នុងទឹក ឆ្អឹងជនរងគ្រោះមិនទាន់បានគាស់មួយចំនួន កប់នៅទីតាំងសម្លាប់ប៉ែកខាងត្បូងកោះ ក៏បានធ្លាក់ចូលក្នុងទន្លេដែរ ។ ចំណែកឆ្អឹងដែលនៅសេសសល់ពីការធ្លាក់ចូលក្នុងទន្លេ ត្រូវប្រជាជនគាស់ចេញពីរណ្តៅ ហើយត្រូវជញ្ជូនយកទៅតម្កល់ទុកនៅមន្ទីរបូជនីយដ្ឋានមួយក្នុងវត្តរការកោង ។ ទុយ ប៊ុន បានសន្និសដ្ឋានថា ខ្មែរក្រហមបានសម្លាប់ជនរងគ្រោះអស់រាប់ពាន់នាក់នៅលើទីតាំងសម្លាប់កោះមរណៈ ។ ផល ថុន មេកងជីវពលឃុំរការកោងទី១បានប្រាប់ថា អដ្ឋិធាតុដែលកំពុងតែដាក់តម្កល់នៅក្នុងបូជនីយដ្ឋាននេះ គឺបានគាស់ឡើងនៅឆ្នាំ១៩៨២ ។

**អ្នកផ្តល់ព័ត៌មានៈ**

១) ផល ថុន មេកងជីវពលឃុំរការកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ។

២) ទុយ ប៊ុន អាយុ៤៤ឆ្នាំ ភេទប្រុស រស់នៅភូមិរការកោង ឃុំរការកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 50' 49:07", រយៈទទឹង (E) 104º 59' 40:69" និងលេខកូដ (ID No.) 080701 ។

## ៤៤) វត្តស្ពួនពេជ្រ

វត្តស្ពួនពេជ ស្ថិតនៅភូមិស្ពួនពេជ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។ វត្តស្ពួនពេជ្រ ជាទីតាំងសម្លាប់ និងមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ នៅក្រោយឆ្នាំ១៩៧៩ ឆ្អឹងលលាដ៍ក្បាល និងឆ្អឹងអវៈយវៈមួយចំនួន ត្រូវបានរើសយកមកដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានមួយក្នុងបរិវេណវត្តនេះ ។

តាមសម្ដីរបស់ គីម សែ អាយុ ៥៨ឆ្នាំ រស់នៅភូមិស្នួនពេជ្រ ឃុំកន្ទោក បានឲ្យដឹងថា ឆ្អឹងដែលដាក់តម្កល់នេះ គឺត្រូវប្រជាជនយកមកពីទីតាំងសម្លាប់ក្បែរៗវត្ត ។ តាមរបាយការណ៍របស់ក្រុមស្រាវជ្រាវផែនទីរណ្ដៅសាកសពជំនាន់ខ្មែរក្រហមបានបញ្ជាក់ថា ដោយសារតែមានអដ្ឋិធាតុតិចតួច ការកសាងមន្ទីរបូជនីយដ្ឋានថ្មីមិនត្រូវបានសាងសង់ឡើយ ។

*អ្នកផ្ដល់ពត៌មានៈ*

១) គីម សែ អាយុ ៥៨ឆ្នាំ ជាអនុប្រធានភូមិត្នោតពង ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

២) ជួប ហួរ អាយុ៥៦ឆ្នាំ រស់នៅភូមិស្នួនពេជ្រ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 30' 33:87", រយៈទទឹង (E) 104º 46' 24:42" និងលេខកូដ (ID No.) 080802 ។

## ៤៥) វត្តភ្នំឧត្តុង្គ

មន្ទីរបូជនីយដ្ឋានធ្វើអំពីឈើប្រក់ក្បឿងមួយកន្លែងរបស់ស្រុកពញាឮ បានត្រូវសាងសង់ឡើងក្បែរជើងភ្នំអង្គបុស ហៅភ្នំឧត្តុង្គ ។ មន្ទីរនេះមានដាក់តម្កល់អដ្ឋិធាតុយ៉ាងច្រើនដែលបានមកពីការជីកគាស់រណ្ដៅសាកសពកាលពីអំឡុងឆ្នាំ១៩៨០ ។ អដ្ឋិធាតុភាគច្រើន ត្រូវប្រជាជនជញ្ជូនមកពីទីតាំងសម្លាប់ចម្ការស្វាយ ។ រិន រើន អាយុ៤២ឆ្នាំ សព្វថ្ងៃនៅភូមិថ្កុកត្របែក ឃុំបាត ស្រុកពញាឮ ខេត្តកណ្ដាល បានប្រាប់ថា នៅទីតាំងចម្ការស្វាយមានជនរងគ្រោះស្លាប់ចំនួនប្រហែល៧០០០នាក់ ។ កាលពីឆ្នាំ២០០២ និង២០០៣កន្លងទៅ ក្រុមធ្វើកោសល្យវិច័យឆ្អឹងជនរងគ្រោះក្រោមរបបខ្មែរក្រហម បានចុះមកកាន់ទីនេះ ដើម្បីសុំការអនុញ្ញាតិពិនិត្យឆ្អឹងលលាដ៏ក្បាល និងឆ្អឹងអវៈយវៈដែលមានតម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានដ៏ធំនេះ ។

*អ្នកផ្ដល់ពត៌មានៈ*

១) រិន រើន អាយុ ៤២ឆ្នាំ សព្វថ្ងៃនៅភូមិថ្កុកត្របែក ឃុំបាត ស្រុកពញាឮ ខេត្តកណ្ដាល ។

២) សុខ ឡេង អាយុ៤៨ឆ្នាំ រស់នៅភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 47' 43:21", រយៈទទឹង (E) 104º 46' 14:30" និងលេខកូដ (ID No.) 080901 ។

## ៤៦) វត្តអង្គសេរីសួរស្ដី

មន្ទីរបូជនីយដ្ឋានចាស់ទ្រុឌទ្រោមមួយនៅវត្តអង្គសេរីសួរស្ដី បានដាក់តម្កល់អដ្ឋិធាតុយ៉ាងច្រើនដែលត្រូវបានគាស់ចេញពីទីតាំងសម្លាប់នៅជ្រលងគ្រើង ដែលស្ថិតនៅតាមដងផ្លូវពីព្រែកព្នៅទៅកាន់ភ្នំ

ប្រសិទ្ធិត្រៃត្រឹង្គ ។ ស៊ិន ទូច អាយុ៥៣ឆ្នាំ ជុំ សាមឿន និង អ៊ឹង ជិន អាយុ៥៤ឆ្នាំ គឺជាអ្នកធ្លាប់ចូលរួមគាស់រណ្ដៅសាកសពនៅប្រឡាយគាប៊ិ និងនៅជ្រលងត្រើយដោយផ្ទាល់ និងជាអ្នកដែលជញ្ជូនឆ្អឹងសាកសពតាមរទេះមកដាក់នៅក្នុងបូជនីយដ្ឋានវត្តអង្គសេរីសួស្ដី ។ គោលបំណងនៃការគាស់រណ្ដៅសាកសពរបស់ពួកគាត់ គឺដើម្បីរកមាស និងវត្ថុមានតម្លៃផ្សេងទៀតចេញពីរាងកាយសាកសព ។ ចំណែក កេត ចន្ថា បានប្រាប់ថា គាត់ជាអ្នកចុះទៅស្រង់ឆ្អឹងចេញពីលូរទឹកនៃជ្រលងត្រើងដោយផ្ទាល់ដៃ ដើម្បីរកមាស ។ ចន្ថា បន្តថា "ខ្ញុំស្រង់បានប្រហែល៩០លលាដ៏ក្បាលប៉ុណ្ណោះពីក្នុងជ្រលងនេះ នៅមានច្រើនទៀតដែលខ្ញុំមិនបានស្រង់" ។ ការគាស់រណ្ដៅសាកសពទាំងពីរកន្លែងនេះ គឺធ្វើឡើងនៅក្នុងឆ្នាំ១៩៨៣ ។ អដ្ឋិធាតុទាំងអស់ត្រូវនាំយកទៅដាក់តែមួយកន្លែង គឺវត្តអង្គសេរីសួរស្ដី ។ អ៊ុម ជិន ក៏បានចូលរួមដឹកឆ្អឹងតាមរទេះក្របីមកដាក់នៅវត្តអង្គសេរីសួស្ដីដែរ ។ ជិន រៀបរាប់ថា គាត់ដឹងតែមួយរទេះទេ ហើយរទេះរបស់គាត់ផ្ទុកបានត្រឹមតែ១៥០ទៅ២០០លលាដ៏ក្បាលប៉ុណ្ណោះ ។

**អ្នកផ្ដល់ព័ត៌មានៈ**

១) ស៊ិន ទូច អាយុ៥៣ឆ្នាំ ភេទប្រុស រស់នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្ដាល ។

២) ជុំ សាមឿន រស់នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្ដាល ។

៣) អ៊ឹង ជិន អាយុ៥៤ឆ្នាំ រស់នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្ដាល ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 40' 58:14", រយៈទទឹង (E) 104º 49' 56:40" និងលេខកូដ (ID No.) 080904 ។

## ៤៧) បាសិដ្ឋត្រៃត្រឹង្គ

មន្ទីរបូជនីយដ្ឋានធ្វើអំពីស៊ីម៉ងត៍ប្រក់ក្បឿងមួយកន្លែង ត្រូវបានធ្វើឡើងនៅលើកំពូលភ្នំប្រាសាទត្រៃត្រឹង្គ ។ មន្ទីរនេះមានទំហំប្រមាណ៣ម៉ែត្រក្រឡា និងមានធ្វើតម្កល់អដ្ឋិធាតុតូចល្មមនៅពីក្នុងមន្ទីរ ។ មាននៅសេសសល់ឆ្អឹងអវៈយវៈបន្តិចបន្តួចប៉ុណ្ណោះនៅក្នុងមន្ទីរបូជនីយដ្ឋាននេះ ។ ខ្នោះឃ្នៀងខ្វះក៏ត្រូវបានជញ្ជូនយកមកដាក់នៅលាយឡំជាមួយអដ្ឋិធាតុទាំងនេះដែរ ។ លោកតា ឃ្មោក មាស អាយុ៥៨ឆ្នាំ រស់នៅភូមិតាពេជ ឃុំឃ្លាំង ស្រុកពញាឮបានប្រាប់ថា ខ្មែរក្រហមបានសម្លាប់មនុស្សនៅតាមជើងភ្នំ និងលើភ្នំ ហើយនៅក្រោយឆ្នាំ១៩៧៩ រណ្ដៅទាំងនោះត្រូវបានគាស់ ។

**អ្នកផ្ដល់ព័ត៌មានៈ**

ឃ្មោក មាស អាយុ៥៨ឆ្នាំ រស់នៅភូមិតាពេជ ឃុំឃ្លាំង ស្រុកពញាឮ ខេត្តកណ្ដាល ។

**ទិន្នន័យកុំព្យូទ័រៈ**

*រយៈកម្ពស់* (N) 11º 34' 59:90", *រយៈទទឹង* (E) 104º 44' 55:69" *និងលេខកូដ* (ID No.) 080907 ។

### ៤៨) កោះគរ

*មន្ទីរសន្តិសុខកោះគរ គ្រាន់តែជាមន្ទីរឃុំឃាំងអ្នកទោសបណ្តោះអាសន្នរបស់ខ្មែរក្រហមប៉ុណ្ណោះ មុននឹងខ្មែរក្រហមបញ្ជូនអ្នកទោសទាំងនោះទៅកាន់ទីតាំងសម្លាប់ ។ រណ្តៅចំនួន៥កន្លែង និងកន្លែងដាក់អដ្ឋិធាតុមួយធ្វើពីឈើដែលមានឆ្អឹងខ្មោចចំនួនច្រើនជាង១.០០០ ត្រូវបានបង្ហាញដោយអ្នកគ្រប់គ្រងមន្ទីរអភិវឌ្ឍន៍កោះគរ ។ នៅទីនោះមានលលាដ៏ក្បាលមួយចំនួន ប៉ុន្តែអ្នកគ្រប់គ្រងបានឲ្យពត៌មានថាលលាដ៏ក្បាលមួយភាគធំត្រូវនាំយកពីកន្លែងដាក់អដ្ឋិធាតុនេះទៅដាក់នៅក្នុងវត្តជាច្រើនក្នុងតំបន់នេះ ។ តាមការប៉ាន់ស្មាន អ្នកទោសដែលត្រូវបានកងឈ្លបសម្លាប់នៅទីនោះ មានប្រហែលពី៥,០០០ទៅ៧,០០០នាក់ ។*

***អ្នកផ្តល់ពត៌មានៈ*** *គ្មាន*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់*(N) 11º 24' 11", *រយៈទទឹង*(E) 105º 01' 03", *លេខកូដ* (ID No.) 081003 ។

### ៤៩) កោះថ្មី

*អ្នកស្រី សុខ បុល ជាមេឃុំខ្ទបបានបង្ហាញប្រាប់ពីសំណង់វត្ត និងសាលាដែលបាក់បែកថា ទីនេះជាអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ ក្នុងឆ្នាំ១៩៧៦ ប្រជាជនជម្លៀសជាច្រើន ព្រមទាំងប្រជាជនមូលដ្ឋានផង ត្រូវខ្មែរក្រហមចាប់បញ្ជូនមកមន្ទីរឃុំឃាំង និងសម្លាប់នៅទីនេះដែរ ។ សុខ បុល បានប្រាប់ផ្ទះបែកបាក់មួយខ្នងដែលជាកន្លែងដាក់អដ្ឋិធាតុជនរងគ្រោះដែលគាត់បានពីរណ្តៅជិតៗនោះថា ធ្លាប់ត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរឃុំឃាំងអ្នកទោស ។*

***អ្នកផ្តល់ពត៌មានៈ*** *គ្មាន*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់*(N) 11º 14' 23:5", *រយៈទទឹង*(E) 105º 01' 55", *លេខកូដ* (ID No.) 081005 ។

## ភ្នំពេញ

### ៥០) ទួលស្លែង

*ក្រោយពេលរៀបចំឡើងវិញបន្ទាប់ពីបរាជ័យរបស់ខ្មែរក្រហម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មន្ទីរសន្តិសុខទួលស្លែងបានក្លាយទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ហើយបានចាប់*

ផ្ដើមដំណើរការបើកទ្វារឲ្យភ្ញៀវចូលទស្សនារហូតមក ដោយមានភ្ញៀវជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ បានចូលមកទស្សនានៅសារមន្ទីរនេះ ។ ចំនួនភ្ញៀវទេសចរដែលចូលមកទស្សនា មាន២ដំណាក់កាលគឺ ដំណាក់កាលទី១ៈ ក្រោយឆ្នាំ១៩៧៩ ដែលជាសម័យកាលគ្រប់គ្រងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា អ្នកដែលមកទស្សនាភាគច្រើនគឺជាភ្ញៀវជាតិ ។ ចំណែកភ្ញៀវបរទេសច្រើនតែជាភ្ញៀវមកពីប្រទេសសង្គមនិយមដូចជា វៀតណាម សូវៀត ឡាវ ហុងគ្រី ប៉ូឡូញ និងបណ្ដាប្រទេសនៅអឺរ៉ុបខាងកើតជាដើម ។ ដំណាក់កាលទី២ៈ ក្រោយពេលបោះឆ្នោតឆ្នាំ១៩៩៣ ដែលជាសម័យកាលស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះរាជាណាចក្រកម្ពុជា ភ្ញៀវទេសចរភាគច្រើនគឺជាភ្ញៀវមកពីប្រទេសតៃវ៉ាន់ ជប៉ុន បារាំង អាល្លឺម៉ង់ កូរ៉េ អាមេរិក អង់គ្លេស និងបណ្ដាប្រទេសប៉ែកខាងលិចមួយចំនួនផង ។

មកដល់បច្ចុប្បន្ននេះ ឆ្អឹងលលាដ៏ក្បាលដែលពីមុនត្រូវបានយកធ្វើជាផែនទីប្រទេសកម្ពុជាសម្រាប់សម្គាល់ការសម្លាប់រង្គាលរបស់ខ្មែរក្រហមក្នុងអំឡុងពេលដែលពួកខ្លួនកាន់អំណាចត្រូវបានរុះរើ បន្ទាប់ពីផែនទីរណ្ដៅសាកសពមួយដែលផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ២០០០ ត្រូវបានដាក់ជំនួសវិញ ។ ឆ្អឹងដែលរុះរើទាំងនេះ ត្រូវបានថែរក្សាទុកយ៉ាងត្រឹមត្រូវនៅក្នុងទូរកញ្ចក់ក្បែរផែនទីរណ្ដៅសាកសពដែលដាក់ព្យួរនៅជញ្ជាំងអែបគ្នានោះ ។ លើសពីនេះទៀត ឆ្អឹងលលាដ៏ក្បាលចំនួន១០ទៀតដែលបាននាំយកមកពីមន្ទីរបូជនីយដ្ឋានអំពែរភ្នំ ភ្នំទត្តុង និងវត្តសូរភី ហៅ វត្តកកោះ ក៏ត្រូវដាក់តាំងក្នុងប្រអប់ចំនួន១០ដែរ នៅក្នុងសារមន្ទីរជាតិទួលស្លែង បន្ទាប់ពីលលាដ៏ក្បាលទាំងនេះត្រូវបានធ្វើកោសល្យវិច័យរួចដោយក្រុមអ្នកជំនាញធ្វើកោសល្យវិច័យឆ្អឹង ។ លលាដ៏ក្បាលទាំង១០ដែលដាក់តាំងនេះ គឺបានបង្ហាញពីការសម្លាប់រង្គាលតាមប្រភេទផ្សេងៗជាច្រើន ដូចជាត្រូវស្លាប់ដោយបាញ់ប្រហារពីលើលលាដ៏ក្បាល វាយនឹងដំបង វាយនឹងខ្នងពូថៅ កាប់នឹងកាំបិត ។ល ។

**អ្នកផ្ដល់ព័ត៌មានៈ** គ្មាន

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់(N) 11º 32' 54:64", រយៈទទឹង(E) 104º 55' 04:54", លេខកូដ (ID No.) 120101 ។

## ៥១) ជើងឯក

មន្ទីរបូជនីយដ្ឋានដ៏ធំមួយ ត្រូវបានសាងសង់ពីបេតុងនៅចំកណ្ដាលទីតាំងវាលពិឃាតជើងឯកដែលស្ថិតនៅក្នុងភូមិរលួស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ កាលពីអំឡុងទសវត្សរ៍ឆ្នាំ[១៩៨០] រណ្ដៅសាកសពចំនួន៨៦នៃចំនួនរណ្ដៅទាំងអស់១២៩នៅទីតាំងវាលពិឃាតជើងឯក ត្រូវបានគាស់ ហើយសាកសពចំនួន៨,៩៨៥នាក់ ត្រូវបានរកឃើញ និងស្រង់ចេញពីរណ្ដៅ ។ ឆ្អឹងដែលគាស់បានទាំងនោះត្រូវបានជញ្ជូនយកទៅដាក់នៅមន្ទីរបូជនីយដ្ឋានមួយដែលធ្វើឡើងពីឈើប្រក់សង្កសី ។ មន្ទីរបូជនីយដ្ឋាន

*នេះមានពីរជាន់ គឺជាន់លើសម្រាប់ដាក់លលាដ៏ក្បាលសាកសព និងជាន់ក្រោមសម្រាប់ដាក់ឆ្អឹងអវៈយវៈ ។ សម្លៀកបំពាក់ដែលស្រោបជាប់នឹងឆ្អឹងសាកសព ត្រូវបានប្រមូល និងគរទុកមួយកន្លែងក្បែរមន្ទីរបូជនីយដ្ឋាននោះ ។ គួររំពឹកថា នៅក្នុងអំឡុងពេលដែលគ្រប់គ្រងដោយរបបខ្មែរក្រហម អ្នកទោសប្រមាណ ១៧០០០នាក់ដែលបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខទួលស្លែង ត្រូវបញ្ជូនយកទៅសម្លាប់នៅទីតាំងវាលពិឃាតជើងឯក ហើយនៅឆ្នាំ១៩៧៨ ការសម្លាប់បានកើតឡើងខ្លាំងជាងឆ្នាំមុនៗ ។ អ្នកទោសទាំងអស់ត្រូវបញ្ឈាឲ្យរង់ចាំរយៈពេលយ៉ាងយូរមួយថ្ងៃនៅទីតាំងវាលពិឃាតជើងឯក មុននឹងខ្មែរក្រហមបញ្ជូនពួកគេទៅសម្លាប់ ។*

*រយៈពេលក្រោយមកទៀត មន្ទីរបូជនីយដ្ឋានដែលសង់អំពីឈើប្រក់សង្កសីត្រូវបានរុះរើ ហើយមន្ទីរបូជនីយដ្ឋានធ្វើអំពីថ្មថ្មីត្រូវបានសាងសង់ឡើងជំនួសមន្ទីរបូជនីយដ្ឋានចាស់ ។ អដ្ឋិធាតុទាំងអស់ ត្រូវនាំយកមកពីមន្ទីរចាស់មកតម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានថ្មីយ៉ាងមានរបៀបរៀបរយ និងអាចថែរក្សាបានគង់វង់យូរអង្វែង ។*

*អ្នកផ្តល់ពត៌មានៈ* *គ្មាន*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់*(N) 11º 29' 2:36", *រយៈទទឹង*(E) 104º 54' 8:02", *លេខកូដ* (ID No.) 120501 ។

# ព្រៃវែង

## ៥២) ភ្នំកំផ្លុក

*ភ្នំកំផ្លុក ស្ថិតនៅភូមិស្វាយសាមសិប ឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង ។ នៅខែតុលា ឆ្នាំ ១៩៩៥ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅកាន់ទីតាំងសម្លាប់ និងមន្ទីរបូជនីយដ្ឋានក្បែរភ្នំកំផ្លុក ។ រណ្តៅប្រមាណ២៥០ ត្រូវបានគាស់ ។ ឆ្អឹងដែលគាស់បានត្រូវប្រជាជនជញ្ជូនមកដាក់នៅក្នុងមន្ទីរបូជនីយដ្ឋានដែលបានសង់ក្បែរនោះ ។ ឥឡូវនេះ អដ្ឋិធាតុទាំងប៉ុន្មានត្រូវបានបំផ្លាញ និងសត្វពាហនៈស៊ី ។ ចាន់ យួន ជាប្រជាជនមូលដ្ឋានដែលបានរស់នៅទីនោះដែរ បានរំពឹកថា គាត់បានឃើញរថយន្តធំៗពីរគ្រឿងដឹកមនុស្សប្រុសស្រី និងកូនក្មេងមកឈប់នៅទីតាំងភ្នំកំផ្លុក នៅពេលដែលគាត់បានទៅបេះបន្លែ និងបោចវល្លិកាលពីក្នុងរដូវប្រាំងនៅចុងឆ្នាំ១៩៧៧ ។ ខ្មែរក្រហមបាននាំប្រជាជនទៅកាន់រណ្តៅ ហើយបានវាយអ្នកទោសសម្លាប់ដោយប្រើភ្លៅរទេះ និងត្បូងចប ។*

*អ្នកផ្តល់ពត៌មានៈ*

*ចាន់ យួន រស់នៅភូមិស្វាយសាមសិប ឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង ។*

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់*(N) 11º 49' 29", *រយៈទទឹង*(E) 105º 21' 48", *លេខកូដ* (ID No.) 140101 ។

## ៥៣) វត្តពាម

*វត្តនេះ ស្ថិតនៅក្នុងភូមិពាមកោះ ឃុំពាមរ ស្រុកពាមរ ខេត្តព្រៃវែង ។ កាលពីឆ្នាំ១៩៩៥ មន្ទីរបូជនីយដ្ឋាននៅវត្តពាម នៅមានសភាពថ្មីនៅឡើយ ហើយអដ្ឋិធាតុតិចតួចដែលដាក់តម្កល់នៅខាងក្នុងមន្ទីរនេះ ក៏អាចជៀសផុតពីសត្វពាហនៈស៊ីដែរ ។ តាមសាក្សី(មិនស្គាល់ឈ្មោះ) បានឲ្យដឹងថា អដ្ឋិធាតុត្រូវបាននាំយកមកពីទីតាំងសម្លាប់នៅវត្តជ្រោយ ។*

*អ្នកផ្តល់ព័ត៌មានៈ គ្មាន*

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់*(N) 11º 18' 49", *រយៈទទឹង*(E) 105º 16' 59", *លេខកូដ* (ID No.) 140701 ។

## ៥៤) វត្តស្វា

*វត្តស្វា មានចម្ងាយ១០គីឡូម៉ែត្រពីសាលាស្រុក ស្ថិតនៅក្នុងភូមិស្វា ឃុំកំពង់ឫស្សី ស្រុកពារាំង ខេត្តព្រៃវែង ។ ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅដល់មន្ទីរបូជនីយដ្ឋានមួយដែលមានទីតាំងនៅក្នុងវត្តនេះ ។ កាលពីឆ្នាំ១៩៧៦ វត្តស្វាត្រូវបានបំផ្លាញដោយកងឈ្លបខ្មែរក្រហម ហើយកុដិត្រូវបានប្រើប្រាស់ធ្វើជាផ្ទះស្នាក់នៅរបស់កងឈ្លបទាំងនោះ ។ ជនរងគ្រោះទាំងអស់ត្រូវខ្មែរក្រហមបញ្ជូនមកកាន់ទីនេះតាមរទេះគោ និងថ្មើរជើង ហើយក្រោយមកត្រូវបានសម្លាប់នៅនឹងទីតាំងនេះតែម្តង ។ មានរណ្តៅសាកសពរួមចំនួន៨៦រណ្តៅ ហើយដែលរណ្តៅសាកសពខ្លះត្រូវបានគាស់រួចហើយកាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ។ អដ្ឋិធាតុដែលគាស់បាន ត្រូវប្រមូលយកមកដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានវត្តស្វា ។ កាលពីឆ្នាំ១៩៩៥ ទីតាំងនេះមានសភាពចាស់ទ្រុឌទ្រោមណាស់ទៅហើយ ហើយអដ្ឋិធាតុដែលនៅសេសសល់ខាងក្នុងមន្ទីរ ក៏មិនទទួលបានការថែទាំឲ្យបានល្អដែរ ។ តាមសង្ឃដីការបស់ចៅអធិការវត្តស្វាបានឲ្យដឹងពីចំនួនមនុស្សស្លាប់ក្នុងបរិវេណវត្តកាលពីរបបខ្មែរក្រហមថា មានចំនួន៩,២៥០នាក់ ព្រោះព្រះអង្គបានឃើញចំនួននេះសរសេរទុកនៅជញ្ជាំងកុដិ ។*

*អ្នកផ្តល់ព័ត៌មានៈ*

*ទៀប ឡេង ភេទប្រុស [រស់នៅភូមិស្វា ឃុំកំពង់ឫស្សី ស្រុកពារាំង ខេត្តព្រៃវែង] ។*

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់*(N) 11º 35' 26", *រយៈទទឹង*(E) 105º 12' 46", *លេខកូដ* (ID No.) 140803 ។

# ពោធិ៍សាត់

## ៥៥) វត្តរំលេច

*កាលពីឆ្នាំ១៩៩៧ លោក ជួង សួរ អាយុ៥៨ឆ្នាំ ជាប្រធានឃុំរំលេច និយាយថា អដ្ឋិធាតុដែលបានគាស់ចេញពីទីតាំងសម្លាប់កូនក្មេង វាលតារាងបាល់ និងខាងលិចសាលារៀនភូមិរំលេច ត្រូវនាំយកមកដាក់តម្កល់នៅក្នុងបរិវេណវត្តរំលេច ឬវត្តចន្ទរង្សីរស្មីរំលេច ស្ថិតក្នុងភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ដែលមានចម្ងាយពីសាលាស្រុកបាកាន១៥គីឡូម៉ែត្រ ដើម្បីទុកធ្វើជាទីសម្រាប់គោរពវិញ្ញាណក្ខន្ធអ្នកដែលបានចែកឋានទៅ និងដាក់ខ្ទែងរំឭកទិវាថ្ងៃ២០ ឧសភា ។ អ៊ុំ ហាក់ បាន និយាយប្រាប់អ្នកសារព័ត៌មានរបស់កាសែតរស្មីកម្ពុជាថា ប្រជាជន និងរដ្ឋអំណាចមូលដ្ឋានបាននាំគ្នាជីកកកាយរណ្តៅសាកសពរួមនៅតាមទីតាំងដូចខាងលើកាលពីឆ្នាំ១៩៧៩ ហើយអដ្ឋិធាតុដែលគាស់បានត្រូវនាំយកមកដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានវត្តរំលេច ឬវត្ត ច័ន្ទរង្សីរស្មីរំលេច[២] ។ តាមសង្កេតការរបស់ព្រះសង្ឃព្រះនាម តាច សុខ គង់នៅវត្តរំលេចបានឲ្យដឹងថា អដ្ឋិធាតុដែលតម្កល់ទាំងប៉ុន្មាន ត្រូវតាជី និងយាយជីប្រមូលកប់ដីអស់ហើយ ។*

***អ្នកផ្តល់ព័ត៌មានៈ***

*ជួង សួរ អាយុ៥៨ឆ្នាំ ជាមេឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ។*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់*(N) 12º 36' 01:47", *រយៈទទឹង*(E) 103º 41' 48:17", *លេខកូដ* (ID No.) 150103 ។

## ៥៦) ដងរ៉ុង

*ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើដំណើរទៅកាន់មន្ទីរបូជនីយដ្ឋានដែលសង់អំពីថ្មយ៉ាងខ្ពស់មួយដែលខឿនរបស់វាត្រូវបានចាក់គ្រឹះយ៉ាងរឹងមាំ ស្ថិតនៅក្នុងភូមិដងរ៉ុង ឃុំកោះជុំ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ ពុំមានរបាយការណ៍ដែលសរសេរដោយក្រុមស្រាវជ្រាវ(ស៊ិន ឃិន, ភោ ទិព្វ និង ហាក់ សុផល) ស្តីអំពីទីតាំងបូជនីយដ្ឋានដងរ៉ុងនេះទេ ប៉ុន្តែការកំណត់ទីតាំងភូមិសាស្ត្រតាមរយៈម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពីភពលោក*(GPS)*ចំពោះទីតាំងនេះ ត្រូវបានធ្វើឡើងដោយក្រុមស្រាវជ្រាវនេះ ។*

---

*២ ឡាយុំ, ទួលវិសេសញ៉ូវ និងវាលគ្រាចជួរកន្ទែងពិឃាតរបស់ខ្មែរក្រហម ។ កាសែតរស្មីកម្ពុជាៈ បោះពុម្ពនៅភ្នំពេញ ឆ្នាំទី១៨ លេខ៤០២១ ។*

*អ្នកផ្តល់ព័ត៌មានៈ* គ្មាន

**ទិន្នន័យភូមិសាស្ត្រៈ**

*រយៈកម្ពស់*(N) 12º 33' 59", *រយៈទទឹង*(E) 103º 53' 20", *លេខកូដ* (ID No.) 150506 ។

# សៀមរាប

## ៥៧) ឡពិឃាដភ្នំទ្រង់បាត

*ឡពិឃាដភ្នំទ្រង់បាត គឺជាកន្លែងដុតសពមនុស្សកាលពីរបបខ្មែរក្រហម ។ ប្រជាជន១៧មេសាភាគច្រើនបានត្រូវសម្លាប់នៅទីនោះ ។ «ឡពិឃាដ» គ្រាន់តែជាឈ្មោះដែលប្រជាជនគ្រប់គ្នានាំគ្នាហៅបន្ទាប់ពីរបបខ្មែរក្រហមត្រូវដួលរលំប៉ុណ្ណោះ ។ ប្រជាជនបានបកស្រាយថា ប្រជាជនជម្លៀសដែលត្រូវបានសម្លាប់ ត្រូវខ្មែរក្រហមដុតជាមួយនឹងអង្កាមដើម្បីយកផេះ និងកម្ទេចកម្ទីទៅធ្វើជីដាក់ស្រែ ។ យឹម សារឿន អាយុ៤៥ឆ្នាំ រស់នៅភូមិស្ពានស្រែង ឃុំទឹកជុំ ស្រុកក្រឡាញ់ បាននិយាយថា ខ្មែរក្រហមបានដុតមនុស្សរាល់ថ្ងៃ ។ នៅឆ្នាំ១៩៩៨ ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្ភាសជាមួយអតីតអ្នកទោសជិនាន់ខ្មែរក្រហមពីរនាក់ ដែលធ្លាប់បានឃើញហេតុការណ៍ដុតមនុស្សផ្ទាល់ភ្នែកនៅជើងភ្នំទ្រង់បាត ។ បន្ទាប់មក ក្រុមនេះបានថតរូបផ្ទះថ្មចាស់ទ្រុឌទ្រោមមួយនៅជាប់ជើងភ្នំទ្រង់បាតដែលត្រូវបានយកធ្វើជាកន្លែងតម្កល់អដ្ឋិធាតុ ។*

*អ្នកផ្តល់ព័ត៌មានៈ*

*១) យឹម សារឿន អាយុ៤៥ឆ្នាំ រស់នៅភូមិស្ពានស្រែង ឃុំទឹកជុំ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។*

*២) ចិ វ៉ាន់ថន អាយុ៤៣ឆ្នាំ ភេទស្រី រស់នៅភូមិក្រូចគោ ឃុំក្រូចគោខាងលិច ស្រុកក្រឡាញ់ ។*

*៣) វ៉ន សុភី អាយុ៣៩ឆ្នាំ ភេទស្រី រស់នៅភូមិស្ពានស្រែង ឃុំទឹកជុំ ស្រុកក្រឡាញ់ ។*

*៤) សេក ប៊ុនធឿន អាយុ៤៧ឆ្នាំ ភេទប្រុស រស់នៅភូមិគូរគន្ត្រី ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ។*

**ទិន្នន័យភូមិសាស្ត្រៈ**

*រយៈកម្ពស់*(N) 12º 36' 31:06", *រយៈទទឹង*(E) 103º 25' 02:75", *លេខកូដ* (ID No.) 170602 ។

## ៥៨) វត្តខ្សាច់

*វត្តសុវណ្ណបុប្ផារាម ហៅវត្តខ្សាច់ មានទីតាំងស្ថិតនៅក្នុងភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ តាមសន្ទជីការរបស់ព្រះតេជគុណព្រះនាម គីវ ឆាយ ព្រះជន្ម៥៦ព្រះវស្សាគង់នៅវត្តខ្សាច់ថា អ្នកទោសចំនួន១២នាក់ប៉ុណ្ណោះក្នុងចំណោមអ្នកទោសទាំងអស់ដែលជាប់ឃុំឃាំង នៅក្នុង*

សាលារៀនមួយខ្នងស្ថិតក្នុងបរិវេណវត្តខ្សាច់ ត្រូវខ្មែរក្រហមចាប់បញ្ជូនមកដាក់គុកវិញបន្ទាប់ពីពួកគេបានបោះទម្លុះជញ្ជាំងគុករត់ ហើយក្រោយមកត្រូវខ្មែរក្រហមនាំយកទៅសម្លាប់នៅក្នុងអណ្តូងទឹកមួយស្ថិតក្នុងបរិវេណវត្តនេះ ។

ព្រះអង្គ គីវ ឆាយ បានមានសង្ឃដីកាបន្តថា នៅក្រោយឆ្នាំ១៩៧៩ គឺបន្ទាប់ពីព្រះអង្គបានបួសជាសង្ឃមុនគេនៅវត្តខ្សាច់ ព្រះអង្គបានឃើញប្រជាជនជីកគាស់អណ្តូងទឹកនេះ រួចទាញយកសាកសពទាំង១២នាក់នោះមកធ្វើបុណ្យតាមប្រពៃណី ព្រមទាំងដាក់តម្កល់អដ្ឋិធាតុយ៉ាងត្រឹមត្រូវក្នុងចេតីយសម្រាប់ក្រុមគ្រួសារគោរពវិញ្ញាណក្ខន្ធ ។

**អ្នកផ្តល់ពត៌មានៈ**

*គីវ ឆាយ ព្រះជន្ម៥៦ព្រះវស្សា គង់នៅវត្តខ្សាច់ ភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបល្ល័ង្គ ។*

**ទិន្នន័យកុំព្យូទ័រៈ**

*រយៈកម្ពស់*(N) 13º 17' 33:93", *រយៈទទឹង*(E) 104º 03' 21:45", *លេខកូដ* (ID No.) 170903 ។

## ៥៩) វត្តអដ្ឋិការាម ហៅ វត្តថ្មី

វត្តអដ្ឋិការាម ហៅ វត្តថ្មី ស្ថិតនៅក្នុងភូមិត្រពាំងសេះ ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ។ នៅឆ្នាំ១៩៩៥ ពេលដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅស្រាវជ្រាវនៅទីនោះ យើងបានពិនិត្យឃើញមានការជួសជុលវត្តអដ្ឋិការាមជាថ្មីឡើងវិញ ។ អដ្ឋិធាតុជាច្រើនត្រូវបាននាំយកទៅតម្កល់ទុកនៅក្នុងចេតីយ៍ដ៏សមរម្យមួយ ។ ហឿង ឡឿម អាយុ៦៦ឆ្នាំ បានប៉ាន់ស្មានថា មានប្រជាជនចំនួនប្រហែល៨,០០០នាក់ ត្រូវបានសម្លាប់នៅទីនេះ ។

**អ្នកផ្តល់ពត៌មានៈ**

*ហឿង ឡឿម អាយុ៦៦ឆ្នាំ* [*រស់នៅភូមិត្រពាំងសេះ ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប*] ។

**ទិន្នន័យកុំព្យូទ័រៈ**

*រយៈកម្ពស់* (N) 13º 22' 58:75", *រយៈទទឹង* (E) 103º 51' 35:89", *លេខកូដ* (ID No.) 171001 ។

## ៦០) វត្តធម្មយុត្តិ

វត្តធម្មយុត្ត ស្ថិតនៅក្នុងភូមិសាលាកន្សែង ឃុំស្រីដូង ស្រុកសៀមរាប ខេត្តសៀមរាប ។ វត្តនេះត្រូវខ្មែរក្រហមប្រើប្រាស់ជាមន្ទីរឃុំឃាំង ហើយនៅក្រោយឆ្នាំ១៩៧៩ មន្ទីរបូជនីយដ្ឋានមួយត្រូវបានសាងសង់ឡើង ដើម្បីដាក់តម្កល់ឆ្អឹងសាកសពដែលស្លាប់នៅក្នុងបរិវេណវត្តនេះ ។ ឆ្អឹងភាគច្រើនជាឆ្អឹងដែលបែកបាក់ និងពុកផុយ ។ តាមការស្រាវជ្រាវរបស់ក្រុមស្រាវជ្រាវកាលពីឆ្នាំ១៩៩៥ បានឲ្យដឹងថា មន្ទីរ

*បូជនីយដ្ឋានមួយនេះត្រូវបានប្រជាជនចាត់ទុកជាកន្លែងគោរពវិញ្ញាណក្ខ័ន្ធ និងជាកន្លែងប្រារព្ធធ្វើទិវាចងកំហឹងថ្ងៃ២០ឧសភា ។ នៅឆ្នាំ១៩៩០ ទិវាចងកំហឹងបានត្រូវផ្អាក ។*

***អ្នកផ្តល់ព័ត៌មានៈ***

*ពុក ពុន ជាចៅអធិការវត្តធម្មយុត្តិភូមិសាលាកន្សែង ឃុំស្រីដូងកុម ស្រុកសៀមរាប ខេត្តសៀមរាប ។*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់* (N) 13º 21' 53:24", *រយៈទទឹង* (E) 103º 51' 18:39", *លេខកូដ* (ID No.) 171005 ។

# ស្ទឹងត្រែង

## ៦១) គីឡូម៉ែត្រលេខ៤

*មន្ទីរបូជនីយដ្ឋានមួយ ស្ថិតនៅទល់មុខបឹងចោងហោងដែលជាកន្លែងសម្លាប់មនុស្សរបស់ខ្មែរក្រហមត្រង់គីឡូម៉ែត្រលេខ៤ និងស្ថិតនៅក្នុងភូមិរាជានុកូល ឃុំស្ទឹងត្រែង ស្រុក និងខេត្តស្ទឹងត្រែង មានតម្កល់អដ្ឋិធាតុជនរងគ្រោះដែលទំនងជាត្រូវបានគាស់ចេញពីរណ្តៅសាកសពចំនួន៩កាលពីឆ្នាំ១៩៧៩ ។ នៅឆ្នាំ១៩៩៥ ពេលដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅដល់ទីកន្លែងនោះ យើងសង្កេតឃើញថា មន្ទីរបូជនីយដ្ឋាននេះហាក់ស្ថិតនៅកណ្តាលព្រៃស៊ុបទ្រុប ហើយលោកតា មិន សាន បានត្រួសត្រាយផ្លូវដើម្បីជូនដំណើរក្រុមស្រាវជ្រាវទៅកាន់មន្ទីរនេះ ។*

***អ្នកផ្តល់ព័ត៌មានៈ***

*១) សោម សោភា អាយុ៤០ឆ្នាំ រស់នៅភូមិរាជានុកូល ឃុំស្ទឹងត្រែង ស្រុក និង ខេត្តស្ទឹងត្រែង ។*

*២) មិន សាន អាយុ៧០ឆ្នាំ រស់នៅភូមិរាជានុកូល ឃុំស្ទឹងត្រែង ស្រុក និងខេត្តស្ទឹងត្រែង ។*

***ទិន្នន័យកុំព្យូទ័រៈ***

*រយៈកម្ពស់* (N) 13º 30' 04:54", *រយៈទទឹង* (E) 105º 58' 11:64", *លេខកូដ* (ID No.) 190403 ។

# ស្វាយរៀង

## ៦២) បុស្ស

*តាមរូបថតដែលបានថតដោយក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ១៩៩៧ នៅទីតាំងមន្ទីរបូជនីយដ្ឋាននៅភូមិបុស្ស ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀងបានបង្ហាញថា មន្ទីរនេះនៅសល់តែគ្រោងឆ្អឹងប៉ុណ្ណោះ ។ អដ្ឋិធាតុដែលមានតែឆ្អឹងស្មងដៃ និងជើង ដាក់តម្កល់នៅលើកំដែងមួយនៅចំកណ្តាលរោងនេះ នៅមានសេសសល់តិចតួចណាស់ ។ តាមរបាយការណ៍ដែលសរសេរដោយ*

ក្រុមដដែលនេះបានឲ្យដឹងថា អដ្ឋិធាតុដែលប្រមូលមកដាក់នៅក្នុងមន្ទីរបូជនីយដ្ឋាននេះ ទំនងជាយកមកពីទីតាំងសម្លាប់ទួលកន្ទុយភ្លៃ និងពីមន្ទីរសន្តិសុខបន្ទប់ខ្សាច់ ។

អ្នកផ្តល់ព័ត៌មានៈ

គង់ វស្សា ភេទប្រុស អាយុ៤៨ឆ្នាំ រស់នៅភូមិពោធិ ឃុំមេសថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

ទិន្នន័យកុំព្យូទ័រៈ

រយៈកម្ពស់ (N) 10º 59' 83:20", រយៈទទឹង (E) 106º 05' 37:54", លេខកូដ (ID No.) 200104 ។

## ៦៣) តាណរ

នៅខែតុលា ឆ្នាំ១៩៩៥ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើការនៅក្នុងស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។ នៅទីតាំងនោះមានមន្ទីរបូជនីយដ្ឋានមួយដែលមានកំពូលស្រួច រៀបជាថ្នាក់ៗ ព័ទ្ធជុំវិញដោយកញ្ចក់ ។ ឆ្អឹងលលាដ៍ក្បាលត្រូវរៀបនៅថ្នាក់ខាងលើ ។ ឆ្អឹងស្មងដៃ ស្មងជើង និងឆ្អឹងផ្សេងៗទៀតត្រូវរៀបនៅថ្នាក់បន្ទាប់ ហើយច្រវ៉ាក់ ខ្នោះ និងសម្លៀកបំពាក់ត្រូវរៀបនៅថ្នាក់ក្រោមបង្អស់ ។ សុគាត បានពន្យល់ថា នៅឆ្នាំ១៩៨២ ប្រជាជនបានជីកគាស់រណ្តៅសាកសព ហើយសាកសពខ្លះត្រូវបានបូតឆ្អឹងតែឆ្អឹងចេញពីសាច់ដែលរលួយ និងបន្ទាប់ពីដុះលាងឆ្អឹងស្អាតហើយ ប្រជាជនក៏នាំគ្នាជញ្ជូនឆ្អឹងទាំងនោះទៅដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋាន ។ នៅក្បែរមន្ទីរបូជនីយដ្ឋាននេះ មានរណ្តៅកប់សាកសពរួមចំនួន៣ ដែលត្រូវបានគាស់ក្នុងព្រៃរនាម ។ អតីតមន្ទីរសួរចម្លើយរបស់ខ្មែរក្រហមមួយដែលមានជញ្ជាំងបូកដោយដី ប្រក់ស្លឹកត្នោត និងទ្រដោយសសរជាច្រើន ត្រូវបានរក្សាទុកធ្វើជាផ្នែកមួយនៃវិមានរំលឹកវិញ្ញាណក្ខន្ធ ។

អ្នកផ្តល់ព័ត៌មានៈ

១) ចាន់ សុគាត ភេទប្រុស ជាអនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ [ខេត្តស្វាយរៀង] ។

២) គុន កែម អាយុ៥៥ ឆ្នាំ រស់នៅ[ភូមិតាណរ ឃុំស្វាយអន្ទរ ស្រុកកំពង់រោទ៍] ។

៣) តា អែម [រស់នៅភូមិតាណរ ឃុំស្វាយអន្ទរ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង] ។

៤) មាស អុក [រស់នៅភូមិតាណរ ឃុំស្វាយអន្ទរ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង] ។

ទិន្នន័យកុំព្យូទ័រៈ

រយៈកម្ពស់ (N) 11º 04' 09", រយៈទទឹង (E) 105º 49' 54", លេខកូដ (ID No.) 200201 ។

## ៦៤) វត្តឫស្សីសាញ់

ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅដល់មន្ទីរបូជនីយដ្ឋានមួយក្បែរវត្តឬស្សីសាញ់ ដែលមានតម្កល់ឆ្អឹងលលាដ៏ក្បាលប្រហែល១០០០ ។ អដ្ឋិធាតុទាំងអស់នេះត្រូវបានថែរក្សាការពារយ៉ាងល្អ ទោះជាមន្ទីរបូជនីយដ្ឋានមួយនេះមានសភាពទ្រុឌទ្រោមណាស់ទៅហើយក៏ដោយ ។ មាត់ យុង អាយុ២៨ឆ្នាំបាននិយាយថា មានរណ្តៅសាកសពចំនួន៣ ដែលត្រូវបានគាស់នៅក្នុងឆ្នាំ១៩៨២ ហើយអដ្ឋិធាតុត្រូវបានយកទៅតម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋាននេះ ។

**អ្នកផ្តល់ពត៌មានៈ**

១) មាស ផន ភេទប្រុស អាយុ៦១ឆ្នាំ រស់នៅភូមិសំឡី ឃុំសំឡី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។

២) សេក សុខុន អាយុ៤៥ឆ្នាំ រស់នៅភូមិតាប៉ៅ ឃុំសសំឡី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។

៣) មុី សាម៉ុល រស់នៅភូមិតាណរ ឃុំស្វាយអន្ទរ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 10º 58' 52", រយៈទទឹង (E) 105º 52' 07", លេខកូដ (ID No.) 200203 ។

## ៦៥) វត្តកំពង់អំពិល

ឆ្អឹងអវៈយវៈ និងឆ្អឹងលលាដ៏ក្បាលចំនួន៤២៥ ត្រូវបាននាំយកទៅដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានមួយដែលស្ថិតនៅក្នុងបរិវេណវត្តកំពង់អំពិល ភូមិកំពង់អំពិល ឃុំកំពង់អំពិល ស្រុករំដួល ខេត្តស្វាយរៀង ។ នៅឆ្នាំ១៩៩២ មន្ទីរនេះត្រូវបានសាងសង់ឡើងដោយមានជញ្ជាំងធ្វើពីបេតុង ដំបូលប្រក់ក្បឿង និងហ៊ុំពទ្ធ័ទៅដោយកំដែងថ្ម ។

**អ្នកផ្តល់ពត៌មានៈ**

១) មាស ធឿន អាយុ៥៤ឆ្នាំ ភេទប្រុស រស់នៅភូមិកំពង់អំពិល ឃុំកំពង់អំពិល ស្រុករំដួល ។

២) រស់ ពត ភេទប្រុស អាយុ៣៥ឆ្នាំ រស់នៅភូមិកំពង់អំពិល ឃុំកំពង់អំពិល ស្រុករំដួល ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 17' 29:97", រយៈទទឹង (E) 105º 48' 22:22", លេខកូដ (ID No.) 200301 ។

## ៦៦) វត្តបាក្រុង

មន្ទីរបូជនីយដ្ឋាននៅក្នុងបរិវេណវត្តបាក្រុងមួយកន្លែង បានត្រូវបំផ្លាញទាំងស្រុង ។ ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅកាន់ទីនោះកាលពីឆ្នាំ១៩៩៧ និងបានសង្កេតឃើញកន្លែងតម្កល់អដ្ឋិធាតុនេះនៅសេសសល់តែគ្រឹះក្រោមជាបេតុងប៉ុណ្ណោះ ហើយអដ្ឋិធាតុទាំងអស់ក៏ត្រូវបាត់បង់អស់ដែរ ។ ក្មេងៗជំនាន់ក្រោយពិតជាមិនដឹងថា កន្លែងនេះជាកន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះដែលត្រូវ

បានសម្លាប់ដោយកងឈ្លបខ្មែរក្រហមឡើយ ។ ឃឹម វ៉ែន ភេទប្រុស អាយុ៥៨ឆ្នាំ រស់នៅភូមិត្រពាំងចំបក់ ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀងបាននិយាយថា គាត់បានទៅចូលរួមគាស់រណ្តៅសាកសពកាលពីឆ្នាំ១៩៨២ ហើយអដ្ឋិធាតុដែលគាស់បានពីទីតាំងសម្លាប់ទួលពពកវិល ត្រពាំងវែង ភូមិទួលច្រេះត្រូវប្រជាជននាំយកទៅដាក់នៅក្នុងមន្ទីរបូជនីយដ្ឋានវត្តបាក្រុង ។

**អ្នកផ្តល់ពត៌មានៈ**

១) ឃឹម វ៉ែន ភេទប្រុស អាយុ៥៨ឆ្នាំ រស់នៅភូមិត្រពាំងចំបក់ ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង ។

២) អ៊ុំ សុន ភេទប្រុស អាយុ៦៩ឆ្នាំ រស់នៅភូមិទួល ពពកវិល ឃុំពពកវិល ស្រុករំដួល ខេត្តស្វាយរៀង ។

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 09' 97:29", រយៈទទឹង (E) 105º 46' 70:33", លេខកូដ (ID No.) 200303

## ៦៧) វត្តកំពង់ត្រាច

ឃុំ សាមុត អាយុ៦០ឆ្នាំ ភេទប្រុស រស់នៅភូមិស្វាយទន្ទឹម ឃុំស្តៅ ស្រុករមាសហែក ខេត្តស្វាយរៀងនិយាយថា ជនរងគ្រោះគ្រប់ប្រភេទ ត្រូវខ្មែរក្រហមសម្លាប់នៅវត្តស្វាយទន្ទឹម ហើយស្ទើរតែគ្រប់រណ្តៅទាំងអស់ត្រូវប្រជាជនគាស់នៅឆ្នាំ១៩៨៣ ។ អដ្ឋិធាតុជនរងគ្រោះដែលគាស់បាន ត្រូវយកទៅដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានវត្តកំពង់ត្រាច ភូមិតាត្រាវ ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ។ រហូតមកដល់ពេលដែល ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះកាន់ទីនោះអដ្ឋិធាតុមាននៅសេសសល់តិចតួចបំផុត ។

**អ្នកផ្តល់ពត៌មានៈ**

១) តក់ ជឹម អាយុ៦៧ឆ្នាំ រស់នៅភូមិស្វាយទន្ទឹម ឃុំត្រពាំងស្តៅ ស្រុករមាសហែក ខេត្តស្វាយរៀង ។

២) ឃុំ សាមុត អាយុ៦០ឆ្នាំ ភេទប្រុស រស់នៅភូមិស្វាយទន្ទឹម ឃុំស្តៅ ស្រុករមាសហែក ខេត្តស្វាយរៀង

**ទិន្នន័យកុំព្យូទ័រៈ**

រយៈកម្ពស់ (N) 11º 24' 59:80", រយៈទទឹង (E) 105º 47' 64:94", លេខកូដ (ID No.) 200401 ។

## ៦៨) វត្តឆ្នក

នៅក្បែរបរិវេណមន្ទីរសន្តិសុខធ្លកនិងជិតវត្តធ្លក មានរណ្តៅកប់សាកសពរួមចំនួន៤១រណ្តៅ ប៉ុន្តែមានតែរណ្តៅ៣ប៉ុណ្ណោះដែលត្រូវបានគាស់កាលពីឆ្នាំ១៩៨២ ។ ឆ្អឹងសាកសពចំនួន៩៣២នាក់ដែលប្រជាជនគាស់បានពីរណ្តៅទាំង៣ ត្រូវបានយកទៅតម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានវត្តធ្លក ដែលមានចម្ងាយប្រហែល១គីឡូម៉ែត្រពីកន្លែងគាស់សាកសព ។ សាក្សីមិនស្គាល់ឈ្មោះម្នាក់បានប៉ាន់ស្មានចំនួនសាកសពដែលមាននៅក្នុងរណ្តៅទាំងអស់ថា មានចំនួនពី១០,០០០ទៅ១៥,០០០នាក់ ។ ក្រៅពីរណ្តៅទាំង៣នេះ រណ្តៅផ្សេងៗទៀត មិនត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាឲ្យជីកឡើយ ព្រោះជាការជីកគាស់រកគ្រឿងអលង្ការផ្សេងៗពីរាងកាយសាកសព ។

*អ្នកផ្តល់ពត៌មានៈ* គ្មាន

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់* (N) 11º 11' 28", *រយៈទទឹង* (E) 105º 44' 17", *លេខកូដ* (ID No.) 200501 ។

## ៦៩) វត្តស្វាយផ្អែម

កាលពីឆ្នាំ១៩៩៥ ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅមើលមន្ទីរបូជនីយដ្ឋានមួយដែលត្រូវបានសាងសង់ឡើងពីឥដ្ឋ និងប្រក់ក្បឿង ស្ថិតនៅក្នុងភូមិស្វាយអង្គ ឃុំស្វាយអង្គ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។ មន្ទីរបូជនីយដ្ឋាននេះ មានតម្កល់ឆ្អឹងអវៈយវៈ និងលលាដ៍ក្បាលជនរងគ្រោះដែលត្រូវបានសម្លាប់ដោយខ្មែរក្រហម ហើយត្រូវបានគាស់ចេញពីរណ្តៅសាកសពដែលស្ថិតនៅក្បែរមន្ទីរបូជនីយដ្ឋាននេះ ។ រណ្តៅកប់សាកសពធំៗចំនួន២កន្លែងស្ថិតនៅវាលស្រែលិចទឹក ត្រូវប្រជាជនគាស់យកឆ្អឹងចំនួនសាកសពចំនួន៤៤ យកទៅតម្កល់ទុកក្នុងមន្ទីរបូជនីយដ្ឋាននេះកាលពីឆ្នាំ១៩៨២ ។

*អ្នកផ្តល់ពត៌មានៈ* គ្មាន

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់* (N) 11º 13' 04", *រយៈទទឹង* (E) 105º 40' 47", *លេខកូដ* (ID No.) 200503 ។

## ៧០) វត្តចាស់

តាមរបាយការណ៍ដែលសរសេរដោយក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីក្រុមនេះបានធ្វើដំណើរទៅកាន់ទីតាំងប្រល័យពូជសាសន៍នានាក្នុងខេត្តស្វាយរៀងកាលពីឆ្នាំ១៩៩៥ គឺពុំបានបញ្ជាក់ពីទីតាំងមន្ទីរបូជនីយដ្ឋានវត្តចាស់ឡើយ ប៉ុន្តែក្រុមនេះបានបញ្ជាក់នៅក្នុងឯកសារដែលកត់ត្រាពីការកំណត់ទីតាំងភូមិសាស្ត្រនៃមន្ទីរបូជនីយដ្ឋានថា រណ្តៅចំនួន៩ដែលស្ថិតនៅជុំវិញបរិវេណមន្ទីរបូជនីយ

ដ្ឋាន ត្រូវបានគាស់ឡើង ហើយឆ្អឹងទាំង១០១ដែលគាស់បាន ត្រូវប្រជាជនដញ្ជូនយកមកថែរក្សាទុកនៅក្នុងមន្ទីរបូជនីយដ្ឋាននេះ ។

**អ្នកផ្តល់ពត៌មានៈ**

១) ទិត ណាង អាយុ៦១ឆ្នាំ

២) សុខ ចេង

**ទិន្នន័យកុំព្យូទ័រៈ**

*រយៈកម្ពស់* (N) 11º 11' 14", *រយៈទទឹង* (E) 105º 42' 36", *លេខកូដ* (ID No.) 200504 ។

## ៧១) វត្តបឹងរ៉ៃ

*រហូតមកដល់ឆ្នាំ១៩៩៥ ចៅអធិការវត្តបឹងរ៉ៃបានប្រើប្រាស់កុដិធំចំនួន២កន្លែងដែលខ្មែរក្រហមធ្លាប់បានប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខធំជាងគេប្រចាំស្រុកស្វាយជ្រុំ ធ្វើជាកុដិសម្រាប់ព្រះសង្ឃគង់ដែលនិង ជាមជ្ឈមណ្ឌលរដ្ឋបាលសម្រាប់បរិវេណវត្តទាំងមូល ។ កុដិទាំងពីរនេះដួសជុលនៅឆ្នាំ១៩៨០ ។ កាលពីឆ្នាំ១៩៨២ ឆ្អឹងលលាដ៏ក្បាលសាកសពចំនួន៣៣០ ដែលគាស់ចេញពីរណ្តៅកប់សាកសពរួមមួយចំនួនក្នុងចំណោមរណ្តៅសាកសពទាំង២៨រណ្តៅដែលស្ថិតនៅក្បែរនោះ ត្រូវបាននាំយកទៅដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋាននៅក្នុងបរិវេណវត្តនេះ ។*

**អ្នកផ្តល់ពត៌មានៈ** គ្មាន

**ទិន្នន័យកុំព្យូទ័រៈ**

*រយៈកម្ពស់* (N) 11º 10' 56", *រយៈទទឹង* (E) 105º 38' 39", *លេខកូដ* (ID No.) 200505 ។

## ៧២) វត្តក្តីរំដួល

*វត្តក្តីរំដួល ស្ថិតនៅភូមិអកនាគ ឃុំសង្ឃរ ស្រុកស្វាយទៀប ខេត្តស្វាយរៀង ។ វត្តនេះត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខក្នុងរបបខ្មែរក្រហម ។ រណ្តៅសាកសពរួមជាច្រើនដែលស្ថិតនៅជុំវិញវត្តនេះត្រូវបានជីកនៅឆ្នាំ១៩៨២ ហើយប្រជាជនបានយកឆ្អឹងទៅតម្កល់ទុកនៅក្នុងមន្ទីរបូជនីយដ្ឋានមួយនៅវត្តក្តីរំដួល ។ នៅពេលដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅដល់ទីនោះកាលពីឆ្នាំ១៩៩៥ ស្តូបនេះហាក់ត្រូវបានបោះបង់ចោល ហើយអដ្ឋិធាតុដែលតម្កល់ទុកនៅក្នុងនោះត្រូវសត្វពាហនៈស៊ីអស់ ។*

**អ្នកផ្តល់ពត៌មានៈ**

*កែម សាមុត* [*រស់នៅភូមិអកនាគ ឃុំសង្ឃរ ស្រុកស្វាយទៀប ខេត្តស្វាយរៀង ។*]

*ទិន្នន័យកុំព្យូទ័រៈ*

*រយៈកម្ពស់* (N) 11º 08' 40", *រយៈទទឹង*(E) 105º 48' 25", *លេខកូដ* (ID No.) 200701 ។

# តាកែវ

## ៧៣) វត្តសូរភី ហៅ កកោះ

*រហូតមកទល់នឹងឆ្នាំ២០០០ នៅពេលដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅស្រាវជ្រាវនៅវត្តសូរភី ហៅ កកោះ វត្តនេះនៅមានបន្សល់ទុកស្លាកស្នាមយ៉ាងច្បាស់ៗនូវស្នាមប៉ះស៊ីម៉ង់ត៍ថ្មីៗគ្រប់រន្ធ ។ ខ្មោះជាច្រើនត្រូវបានដាក់តម្កល់ក្នុងបូជនីយដ្ឋានមួយជាមួយអដ្ឋិធាតុមួយចំនួនដែលត្រូវបានគាស់ដោយប្រជាជននៅជុំវិញបរិវេណវត្តនេះកាលពីឆ្នាំ១៩៨០ ។ សង្ឃដីការរបស់ព្រះតេជគុណ កែវ កុសល ថាអដ្ឋិធាតុដែលបានគាស់រួចមកនេះ ស្មើនឹងមួយភាគប្រាំនៃឆ្អឹងទាំងអស់ ។ កន្លែងតម្កល់អដ្ឋិធាតុ ស្ថិតនៅខាងកើតឈៀងខាងត្បូងព្រះវិហារវត្តកកោះ ។ នៅថ្ងៃ២០ ឧសភា ស្ទើរតែរាល់ឆ្នាំមានព្រះសង្ឃ១០០អង្គ ព្រមទាំងប្រជាជនរាប់ពាន់នាក់ក្នុងស្រុកមកធ្វើបុណ្យឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ទាំងនោះឲ្យទៅកាន់សុគតិភព ។ ថ្មីៗនេះព្រះតេជគុណអង្គនោះបានសាងសង់កុដិមួយនៅក្បែរអតីតរណ្តៅសាកសពទាំងនោះ ហើយព្រះតេជគុណបានជីកដីនៅក្បែរនោះមកតម្កល់ជើងតាង ។ នៅពេលដែលជីកបានជម្រៅប្រហែលកន្លះម៉ែត្រ និងទំហំប្រហែលកន្លះម៉ែត្រ ក៏បានប្រទះឃើញមានខោអាវដែលមិនទាន់ពុកផុយ ព្រមទាំងមានឆ្អឹងមួយចំនួនទៀត ។ ឆ្អឹងនោះមានចំនួនជិតមួយបង្គីរ ហើយភាគច្រើនជាឆ្អឹងស្នូងជើង និងឆ្អឹងដើមដៃ...។ ព្រះតេជគុណបាននាំយកឆ្អឹងទាំងនោះទៅដាក់តម្កល់ជាមួយអដ្ឋិធាតុជាច្រើនទៀតដែលមាននៅក្នុងមន្ទីរបូជនីយដ្ឋាន ។ យប់ថ្ងៃដដែលនោះក៏មានព្រះសង្ឃអង្គផ្សេងស្រម៉ៃឃើញស្ទើរនឹងភ្នែកស្រស់ទាំងកណ្តាលយប់នូវហ្វូងមនុស្សទាំងប្រុស ស្រី ចាស់ ក្មេង នាំគ្នាដើរឡើងសំដៅទៅកាន់ព្រះវិហារវត្តកកោះ ។ ព្រះសង្ឃ កែវ កុសល មានសង្ឃដីការថា ជាព្រលឹងដែលមិនទាន់ស្ងប់របស់ជនរងគ្រោះដើរទាមទារឲ្យមានការសែនសឹង ។*

***អ្នកផ្តល់ព័ត៌មានៈ***

*១) កែវ កុសល ភេទប្រុស អាយុ២៥ឆ្នាំ ជាព្រះសង្ឃគង់នៅវត្តសូរភី ហៅកកោះ ស្រុកបាទី ខេត្តតាកែវ ។*

*២) សូ ញ៉ូវ ភេទប្រុស អាយុ៦៩ឆ្នាំ រស់នៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ។*

*៣) ទឹម គុន ភេទប្រុស អាយុ៥៥ឆ្នាំ រស់នៅភូមិភ្នំតូច ឃុំសូរភី ស្រុកបាទី ខេត្តតាកែវ ។*

*៤) មុយ ចក់ ភេទប្រុស រស់នៅភូមិភ្នំតូច ឃុំសូរភី ស្រុកបាទី ខេត្តតាកែវ ។*

*ទិន្នន័យកុំព្យូទ័រ*

*រយៈកម្ពស់* (N) 11º 16' 45:79", *រយៈទទឹង*(E) 104º 49' 59:25", *លេខកូដ* (ID No.) 210201 ។

## ៧៤) វត្តទ្រព្យគរ

*វត្តទ្រព្យគរ ស្ថិតនៅតាមផ្លូវគ្រួសក្រហមមួយខ្សែដែលលាតសន្ធឹងទៅទិសខាងលិចពីផ្លូវជាតិលេខ២ ត្រង់ផ្សារសំរោងយ៉ោង ឆ្ពោះទៅកាន់ផ្លូវជាតិលេខ៣ត្រង់កាច់ជ្រុងផ្សារត្រាំខ្នារ ។ វត្តនេះកាលពីជំនាន់ ប៉ុល ពត ត្រូវបានខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងមនុស្សបណ្ដោះអាសន្នមុនពេលយកទៅសម្លាប់ចោល ។ លោកតា ប្រាក់ អ៊ឹម អាយុ៧៨ឆ្នាំ រស់នៅភូមិត្រកៀត ឃុំត្រពាំងសាប ស្រុកបាទី និយាយថា ខ្មែរក្រហមបានប្រើប្រាស់វត្តនេះជាមន្ទីរឃុំឃាំងអ្នកទោសបណ្ដោះអាសន្ន មុនពេលដែលអ្នកទោសទាំងនោះត្រូវនាំយកទៅសម្លាប់ចោល ។ លោកតាបន្តថា ក្រៅពីធ្វើជាមន្ទីរឃុំឃាំងបណ្ដោះអាសន្ន វត្តនេះក៏ជាកន្លែងសម្លាប់មនុស្សដែរ ។ នាពេលបច្ចុប្បន្ននេះ ចេតីយ៍ចំនួនពីរនៅក្នុងបរិវេណវត្តទ្រព្យគរ ត្រូវបានប្រើប្រាស់ជាកន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះដែលខ្មែរក្រហមសម្លាប់ ។ នៅឆ្នាំ១៩៨០ ប្រជាជនក្នុងភូមិបាននាំគ្នាទៅគាស់កកាយរណ្តៅសាកសពនៅក្បែរបរិវេណវត្តទ្រព្យគរ ដើម្បីរកមាស និង វត្ថុមានតម្លៃផ្សេងៗពីក្នុងសម្លៀកបំពាក់របស់សាកសព ។ នៅពេលនោះឆ្អឹងមួយចំនួនត្រូវបានចៅហ្វាយស្រុកបញ្ជារឲ្យប្រជាជនរើសយកមកតម្កល់នៅក្នុងចេតីយ៍ចំនួន២នៅខាងជើងព្រះវិហារទ្រព្យគរ ។*

*អ្នកផ្តល់ព័ត៌មានៈ*

*ប្រាក់ អ៊ឹម ភេទប្រុស អាយុ៧៨ឆ្នាំ រស់នៅភូមិត្រកៀត ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ។*

*ទិន្នន័យកុំព្យូទ័រ*

*រយៈកម្ពស់* (N) 11º 16' 32:58", *រយៈទទឹង*(E) 104º 47' 16:08", *លេខកូដ* (ID No.) 210203 ។

## ៧៥) វត្តព្រះធាតុស្នួរស្គី

*វត្តព្រះធាតុស្នួរស្គី មានទីតាំងស្ថិតនៅក្នុងភូមិក្បាលដំរី ឃុំគោកព្រីង ស្រុកគីរីវង្ស ខេត្តតាកែវ ។ វត្តនេះ ត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់របស់ខ្មែរក្រហម ហើយនៅក្រោយឆ្នាំ ១៩៧៩ ជ្រុងមួយនៃសាលាបុណ្យធ្វើពីបេតុង ដែលពីមុនជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហម បានត្រូវជ្រើសរើសធ្វើជាកន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះដែលគាស់បានកាលពីឆ្នាំ១៩៨៤ ។ មកដល់ត្រឹមក្រុមស្រាវជ្រាវយើងចុះទៅកាលពីឆ្នាំ១៩៩៨ អដ្ឋិធាតុស្ទើរតែទាំងអស់ត្រូវបានបំផ្លាញ និងសត្វពាហនៈស៊ី ។*

*អ្នកផ្តល់ព័ត៌មានៈ*

១) លី ជន អាយុ៩៩ឆ្នាំ រស់នៅភូមិក្បាលដំរី ឃុំគោកព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ ។

២) ដាក សាន អាយុ៧៨ឆ្នាំ រស់នៅភូមិក្បាលដំរី ឃុំគោកព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ ។

៣) អ៊ុក យ៉ាន អាយុ៦៨ឆ្នាំ រស់នៅភូមិក្បាលដំរី ឃុំគោកព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ ។

**ទិន្នន័យកុំព្យូទ័រៈ**

*រយៈកម្ពស់* (N) 10º 42' 58:73", *រយៈទទឹង*(E) 104º 45' 36:76", *លេខកូដ* (ID No.) 210401 ។

## ៧៦) វត្តពោធិ៍មាសអណ្តែត

*វត្តពោធិមាសអណ្តែត ស្ថិតនៅភូមិតាលន់ ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ វត្តនេះមានមន្ទីរបូជនីយដ្ឋានដ៏ល្អប្រណិតមួយធ្វើពីបេតុងមានពីរជាន់ ដែលកសាងឡើងក្នុងឆ្នាំ១៩៩៣ ។ មន្ទីរបូជនីយដ្ឋាននេះ មានដាក់តម្កល់អដ្ឋិធាតុជនរងគ្រោះដែលយកមកពីភូមិឫស្សី និងភូមិបំពង់ចាក់ ។*

**អ្នកផ្តល់ពត៌មានៈ** គ្មាន

**ទិន្នន័យកុំព្យូទ័រៈ**

*រយៈកម្ពស់* (N) 10º 08' 24", *រយៈទទឹង*(E) 104º 56' 03", *លេខកូដ* (ID No.) 210602 ។

## ៧៧) វត្តស្រះគ្រាំងបន្ទាយ

*កម្ទេចកម្ទីអដ្ឋិធាតុមួយចំនួន កំពុងតែស្ថិតនៅក្នុងចេតីយ៍មួយក្នុងវត្តស្រះគ្រាំងបន្ទាយ នៅពេលដែលក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅកាន់ទីនោះកាលពីឆ្នាំ១៩៩៧ ។ វត្តនេះមានទីតាំងស្ថិតនៅក្នុងភូមិពេជឥន្ទ្រា ឃុំបឹងត្រាញ់ជើង ស្រុកសំរោង ខេត្តតាកែវ ។ សំ ផុន ភេទប្រុស អាយុ៥២ឆ្នាំ ជាអាចារ្យវត្ត រស់នៅភូមិពេជឥន្ទ្រា ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ បាននិយាយថា ខ្មែរក្រហមបានសម្លាប់ជនរងគ្រោះនៅជុំវិញវត្តស្រះគ្រាំងបន្ទាយ ហើយនៅក្រោយឆ្នាំ១៩៧៩ រណ្តៅសាកសពខ្លះត្រូវបានជីក ដោយនាំយកឆ្អឹងដែលជីកបានមកដាក់នៅក្នុងចេតីយ៍មួយក្បែរស្រះទឹក ។*

**អ្នកផ្តល់ពត៌មានៈ**

១) ទេស បាន រស់នៅភូមិពេជឥន្ទ្រា ឃុំបឹងត្រាញ់ជើង ស្រុកសំរោង ខេត្តតាកែវ ។

២) សំ ផុន រស់នៅភូមិពេជឥន្ទ្រា ឃុំបឹងត្រាញ់ជើង ស្រុកសំរោង ខេត្តតាកែវ ។

**ទិន្នន័យកុំព្យូទ័រៈ** *រយៈកម្ពស់* (N) $11^{0}$ 07'12:97", *រយៈទទឹង* (E) $104^{0}$ 44'23:55", *លេខកូដ*(ID No.) 210702 ។

## ៧៨) ទួលអន្ត

ទួលអន្តស្ថិតនៅក្នុងភូមិក្រាំងស្ពោ ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ ។ ទួលនេះកំពុងស្ថិតក្រោមការសាងសង់ព្រះវិហារ និងរៀបចំសម្អាតបរិវេណជុំវិញ ។ កាលពីឆ្នាំ២០០១ នៅពេលដែលក្រុមស្រាវជ្រាវបានចុះទៅធ្វើការនៅទីនោះ យើងសង្កេតឃើញផ្នូរកប់អដ្ឋិធាតុជនរងគ្រោះមួយនៅលើដីទួលនាបរិវេណវត្តនេះ ។ តាមការបំភ្លឺរបស់ សារ៉ាយ ហ៊ន បានឲ្យដឹងថា មុនដំបូងទីនេះមានកន្លែងតម្កល់អដ្ឋិធាតុត្រឹមត្រូវ ប៉ុន្តែក្រោយមកដោយមានការធ្វេសប្រហែល អដ្ឋិធាតុជាច្រើនត្រូវបានបំផ្លាញ និងសត្វស៊ី ។ ហេតុនេះហើយ ទើបលោកតា សេក ទូន អាយុ៦៦ឆ្នាំ រស់នៅភូមិក្រាំងស្ពោ ឃុំសឹង្ហ បានប្រមូលអដ្ឋិធាតុដែលនៅសេសសល់មកគរទុកម្តុំ រួចក៏យកអដ្ឋិធាតុទាំងនោះទៅកប់ ហើយពូនដីធ្វើជាផ្នូរមួយនៅចំកណ្តាលដីទួលដែលមានទំហំប្រមាណ១០ម៉ែត្របួនជ្រុង ។ រហូតមកដល់ឆ្នាំ២០០១ ផ្នូរកប់អដ្ឋិធាតុនេះមានដាំបង្គោលបួនព័ទ្ធជុំវិញ ហើយមានធ្វើជារបងផង ។ តាំងពីទសវត្សរ៍ឆ្នាំ១៩៨០រហូតមកដល់១៩៩០ ទីតាំងកន្លែងនេះត្រូវបានយកធ្វើជាកន្លែងប្រារព្ធពិធីបុណ្យរំលឹកថ្ងៃ២០ឧសភា ដើម្បីរំលឹកថ្ងៃចងកំហឹងចំពោះរបបខ្មែរក្រហម ។

**អ្នកផ្តល់ព័ត៌មានៈ**

១) សេក ទូន អាយុ៦៦ឆ្នាំ រស់នៅភូមិក្រាំងស្ពោ ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ ។

២) សារ៉ាយ ហ៊ន រស់នៅភូមិក្រាំងស្ពោ ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ ។

**ទិន្នន័យកុំព្យូទ័រៈ** រយៈកម្ពស់ (N) $11^{0}$ 06'06:05", រយៈទទឹង (E) $104^{0}$ 47'52:62", លេខកូដ(ID No.) 210707

## ៧៩) ក្រាំងតាចាន់

ទីចុងបញ្ចប់របស់មន្ទីរអប់រំស្រុកត្រាំកក់របស់ខ្មែរក្រហម បានបន្សល់ទុកនូវរណ្តៅសាកសពរួមចំនួន២១រណ្តៅ និងមានប្រជាជនចំនួន១០,០៤៥នាក់ស្លាប់ ព្រមទាំងអគារគុកចាស់ៗដែលពោរពេញទៅដោយខ្នោះឃ្នាងជាច្រើន ។ សព្វថ្ងៃក្នុងបរិវេណអតីតមន្ទីរអប់រំស្រុកត្រាំកក់ មានរោងដាក់អដ្ឋិធាតុមួយធ្វើពីឈើទំហំទទឹង៣ម៉ែត្រនិង បណ្តោយ៥ម៉ែត្រ និងសាលាឆទាន(សាលាសំណាក់)មួយធ្វើអំពីឈើ ទំហំ៥ម៉ែត្រ និង៨ម៉ែត្រត្រូវរដ្ឋអំណាចសាងសង់ឡើងបន្ទាប់ពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ។ រោងនេះសង់ឡើងដើម្បីប្រារព្ធពិធីបុណ្យប្រចាំឆ្នាំក្នុងភូមិ ដើម្បីឧទ្ទិសមគ្គផលដល់អ្នកដែលបានស្លាប់ក្នុងមន្ទីរអប់រំស្រុកត្រាំកក់នេះ ។ ចាប់តាំងពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២ អដ្ឋិធាតុទាំងអស់ត្រូវបានប្តូរពីអគារឈើដែលមានសភាពចាស់ទ្រុឌទ្រោម ទៅកាន់ទីតាំងអគារថ្មីធ្វើអំពីថ្ម ។ សម្តេច ជា ស៊ីម បានផ្តួចផ្តើមការសាងសង់នេះឡើង ហើយរហូតមកដល់សព្វថ្ងៃនេះ ឈ្មោះថ្មីដែលបានប្រើប្រាស់ជាផ្លូវការគឺ “មណ្ឌលឧក្រិដ្ឋកម្ម

ក្រាំងតាចាន់ ជា ស៊ីម"។ មន្ទីរបូជនីយដ្ឋានថ្មីនេះ មានទំហំខ្សៀន១៥ម៉ែត្រក្រឡា តួស្តូបទំហំ៥ម៉ែត្រក្រឡា និងកម្ពស់១២,៧០ម៉ែត្រ។ តាមកាសែតរស្មីកម្ពុជាចុះថ្ងៃទី[៨ ខែវិច្ឆិកា ឆ្នាំ២០០២] បានឲ្យដឹងថា ការសាងសង់ស្តូបនេះគឺបានចំណាយថវិកាអស់១៣,៩៨៣.៣៣ដុល្លារ។ ថ្វីត្បិតតែមានអដ្ឋិធាតុច្រើនដាក់តម្កល់ក្នុងមន្ទីរបូជនីយដ្ឋាននេះ ប៉ុន្តែនៅពេលថ្មីៗនេះ អដ្ឋិធាតុជាច្រើនទៀតត្រូវបានរកឃើញនិងគាស់ចេញពីក្នុងរណ្តៅនាបរិវេណទីទួលក្រាំងតាចាន់។ យោងតាមកាសែតរស្មីកម្ពុជា លោក ពុត ខ្វៃ ជាតំណាងក្រុមប្រឹក្សាឃុំគូសនិយាយថា ការគាស់កកាយយកឆ្អឹងជនរងគ្រោះដែលស្លាប់កាលពីជំនាន់ខ្មែរក្រហមនៅមិនទាន់បញ្ចប់នៅឡើយទេ។ ខ្វៃ បន្តថា យូរៗម្តងគេប្រទះឃើញគ្រោងឆ្អឹងមនុស្សដែលកប់នៅក្នុងដី។

*អ្នកផ្តល់ព័ត៌មានៈ*

១) ពុត ខ្វៃ ជាតំណាងក្រុមប្រឹក្សាឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។

២) កែវ ម៉ៅ រស់នៅភូមិក្រាំងតាចាន់ ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។

៣) សែន រស់នៅភូមិក្រាំងតាចាន់ ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។

៤) សូត្រ សាំង រស់នៅភូមិក្រាំងតាចាន់ ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។

*ទិន្នន័យភូមិសាស្ត្រៈ* រយៈកម្ពស់ (N) $10^0$ 57'06:59", រយៈទទឹង (E) $104^0$ 35'32", លេខកូដ(ID No.) 210901 ។

## ៨០) ភ្នំសន្ទុង

ភ្នំសន្ទុង ស្ថិតនៅក្នុងភូមិស្រះត្រគួន ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ។ តាមរបាយការណ៍ដែលសរសេរដោយក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ១៩៩៥ថា ទីតាំងនេះកំពុងគ្របដណ្តប់ដោយព្រៃដុះស៊ុបទ្រុប ហើយអគារដែលជាអតីតមន្ទីរសន្តិសុខត្រូវខូចខាតអស់។ លលាដ៍ក្បាលខ្លះត្រូវបានយកទៅដាក់តម្កល់នៅព្រៃផ្អាវ។

*អ្នកផ្តល់ព័ត៌មានៈ* គ្មាន

*ទិន្នន័យភូមិសាស្ត្រៈ* រយៈកម្ពស់ (N) $10^0$ 48'11", រយៈទទឹង (E) $104^0$ 45'58", លេខកូដ(ID No.) 211001 ។

## ៨១) ព្រៃផ្អាវ

ព្រៃផ្អាវ ស្ថិតនៅភូមិព្រៃផ្អាវ ឃុំនាម ស្រុកទ្រាំង ខេត្តតាកែវ។ មន្ទីរបូជនីយដ្ឋានមួយបានត្រូវសាងសង់ឡើងដោយបេតុងប្រក់ក្បឿង មានកម្ពស់ប្រហែល៤ម៉ែត្រ និងទំហំប្រហែល៣ម៉ែត្រក្រឡា។ នៅខាងក្នុងមន្ទីរបូជនីយដ្ឋាននេះ មានឆ្អឹងលលាដ៍ក្បាលប្រហែលជាង១០០ស្ថិតនៅរាយប៉ាយ

*និងគ្មានសណ្តាប់ធ្នាប់ (តាមរបាយការណ៍របស់ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ ១៩៩៥) ។ អដ្ឋិធាតុជាច្រើនបានត្រូវជញ្ជូនមកពីភូមិសន្ទុង និងជុំវិញបរិវេណវត្តជើងចាប ។ ប៉ុន្តែរយៈក្រោយមក អដ្ឋិធាតុភាគច្រើនបានបាត់បង់ និងសត្វស៊ី ។*

***អ្នកផ្តល់ព័ត៌មានៈ*** *គ្មាន*

***ទិន្នន័យកុំព្យូទ័រៈ*** *រយៈកម្ពស់* (N) $10^{0}$ 56'47", *រយៈទទឹង* (E) $104^{0}$ 45'58", *លេខកូដ*(ID No.) 211002 ។